ប្រមូលរួមផ្ដុំ　　នាំគ្នាជំនុំ

ដោះស្រាយបញ្ហា ។

វប្បធម៌ខ្មែរមាន　　គួរប្រើជាយាន

តែនូវភាសា　　ជាតិរបស់យើង

ទើបបានថ្លៃថ្លា　　ឈ្មោះថាខេមរក

ឯកកជតាំងសត្វ ។

(1) ខ្មែរល្អក់នឹងវប្បធម៌បារាំង

★

## សប្បាយរបៀបណាទើបថ្លៃថ្នូរ ?

អ្នកស្រី ព្រំ សំអា

នាទីថ្ងៃយប់　　ទៅមុខគ្មានឈប់

ត្រឡប់ថយក្រោយទេ　　ថ្ងៃសៅរ៍ផុតទៅ

អាទិត្យទំនេរ　　ជនខ្លះគ្នាន់គ្នេរ

ចេញទៅកំសាន្ត ។

រីកសិករ　　សាទរអបអរ

កាលណាបើបាន　　ផលដំណាំច្រើន

ចំរើនគ្រប់ប្រាណ　　ជីវិតក្សេមក្សាន្ត

ផ្អែតល្ងាចផ្អែតព្រឹក ។

កម្មករនានា . . .　　　　បំណងដូចគ្នា
ត្រេកអរពទ្ទឹក　　　　សុខភាពគ្រប់គ្រាន់
មានបាយមានទឹក　　　　ម្នីម្នាពីព្រឹក
ធ្វើការតាមក្រុម ។

ស្របទៅទាំងស្រុង　　　　តាមគោលការណ៍ក្នុង
អង្គការសង្គម　　　　ការងារឲ្យផល
ត្រូវតែនិយម　　　　ទើបបានសង្គម
អាចលឿនប្រពៃ ។

ជនស្នេហ៍ជាតិពិត　　　　ដេកដើររិះគិត
មួយថ្ងៃមួយថ្ងៃ　　　　បើគេបានធ្វើ
ការមានដម្លៃ　　　　នោះអស់សង្ស័យ
ក្នុងចិត្តសប្បាយ ។

សប្បាយដោយបាន　　　　មានលុយមានឡាន
វិមានផ្គត់កាយ　　　　ផ្ទាល់ខ្លួនគ្រួសារ
ដើរលេងស៊ីចាយ　　　　នេះហៅសប្បាយ
នៃអ្នកលោកលន់ ។

សំដៅអាត្មា　　　　សិនសឹមរដ្ឋ
គឺពួកមូលធន　　　　មិនបេះផ្អែតទេ
ពីរឿងទ្រព្យធន　　　　ដូចនេះគឺជន
ណាជ្រោមជ្រែងជាតិ ?

# សុភាសិត នឹងច្បាប់កេរ្តិ៍កាល

សុក ឡាមីង
វិទ្យាល័យជ័យវរ្ម័នទី ៧

ចេះ ព្រោះតែខំរៀនវិជ្ជា
មក ពីឧស្សាហ៍មិនឈរឈប់
ពី ការអំណត់អត់ទល់ទប់
រៀន សូត្រថ្ងៃយប់មិនបោះបង់ ។
មាន ទ្រព្យសម្បត្តិព្រោះឧហាត
មក ពីសង្វាត ទុកដាក់ខ្ជង់
ពី ការសន្សំមិនអែអង់
រក បានប្រាណផ្គង់មិនខ្ជះខ្ជាយ ។

★

ខឹង ច្រើននាំឲយតែវង្វេង
ត្រូវ គំនិតឈ្លេងយល់ ឲយឆ្ងាយ
ខំ សង្កត់ចិត្តចូរទូលាយ
អត់ ទិនដល់កាយគេខ្វះផង ។
ខ្សត់ ហើយគួរប្រឹងប្រែងទុកដាក់
ត្រូវ សន្សំប្រាក់កុំជួជង
ខំ ប្រើគំនិតគិតម៉ត់ហ្មង
រក បានទ្រព្យផងប្រុងថៃថ្នូន ។

★

លោក ប្រាប់ឲ្យដឹងនូវពួកល្បែង
ថា កុំបីលេងនាំបង់ទ្រព្យ
ឆ្កួត វង្វេងប្រាណបានអភ័ព្វ
បី ប្អូនជួនជាប់ថោកអសារ ។

ឆ្កួត មុនដំបូងគឺឆ្កួតស្រី
មួយ នេះឯងនៃត្រូវដកឃ្លា
នឹង នាំអាស្រូវផ្លូវពេគា
ស្រី ពួកពេស្យាមិនគួរគាប់ ។

ឆ្កួត បន្ទាប់មកគឺឆ្កួតស្រា
មួយ ទៀតនេះណាកុំប្រសព្វ
នឹង នាំឆេះឆាបឆាបមិនឈប់
ស្រា ធ្វើឲ្យឡប់ខ្វបស្មារតី ។

ឆ្កួត បីគឺឆ្កួតល្បែងពាលា
មួយ នេះសោតណាហៅថាជ្រៃ
នឹង នាំអាត្មាអាស្រូវក្រៃ
ល្បែង តែងអប្រិយ លែកុំបៀត ។

អំ ណើះតទៅត្រូវវៀរចាក
ពើ បពះមិនស្រាកនាំចោលមៀត
ពា លោប៉ោខ្សែ ស្អុយមារយាទ
លា ចាកឃ្លាឃ្លាត ទើបប្រសើរ ។

ឆ្កួត ទាំងបីយ៉ាង គេពេបជ្រាយ
នេះ គេមើលងាយ ជៀលល្ងីល្ងើ
ហៅ ពេញសំគិះ ព្រោះឆ្កួតក្លើ
មហា ទុក្ខធ្លាក់លើ ផ្ទើឲ្យធ្ងន់ ។

ឆ្កួត កើតអោសាច់ស្អុយជិតជុំ
ក្រែ ណារហុំមិនដឹងអន់
គ សាងបែបនេះពិតខុសគ(១)
នួង ចាស់ទន់ភ្លន់ទុកជាច្បាប់ ។

១— " គ " អានថា " គន់ " ។

★

## សើចស្ងួតបន្តិចចុះ !

— តាយព្រោក: អាសម្លាញ់ ប្រាច ! តើត្រូវធ្វើម៉េច បានពូកែខ្មែរ នឹងគេអ៊ា ?

— តាយប្រាច: ងាយទេ ! ខំរៀន នឹង មើលតែសៀវភៅបារាំងទៅ វាពូកែខ្មែរទៅហើយ ។

— តាយព្រោក: មែនឬ ? អីចឹងបានជាអញឃើញអាប្រុញឃើង ម៉្វៗ វាមើលតែសៀវភៅអង់គ្លេស ស្រាប់តែដល់ពេលវា សរសេរសៀវភៅជាខ្មែរ ហូរមកដូចទឹកទន្លេ ហើយ ករីៗ ប៉ុនសន្ធរម៉ុក សុំខាស . . . ។



# អត្ថបទ & ឯកសារ

## សេដ្ឋកិច្ចនយោបាយ

ម៉ៃ លន់

ទីចាត់ការកិច្ចការគរុកោសល្យ

ទស្សនាវដ្ដីសាស្ត្រាចារ្យមានសេចក្ដីរីករាយ នឹងចុះអត្ថបទរបស់មិត្ត ម៉ៃ លន់ ស្ដីពីសេដ្ឋកិច្ចនយោបាយ ។ មិត្ត ម៉ៃ លន់ បានរៀបចំអត្ថបទនេះឡើង ក្នុងគោលបំណងពីរយ៉ាង :

១— ផ្សាយនូវសញ្ញាណសំខាន់ ៗ ខ្លះ ដែលជាមូលភាពនៃសេដ្ឋកិច្ចនយោបាយ ដើម្បីជាផ្នែកវប្បធម៌ទូទៅមួយ សំរាប់ទស្សនាវដ្ដីយើង ។

២— បង្ហាញនូវលទ្ធភាព នៃភាសាខ្មែរ ដែលអាចយកមកធ្វើជាមធ្យោបាយផ្សាយនូវវប្បធម៌មុខវិជ្ជាផ្សេង ៗ ទៀតបាន ដូចភាសាដទៃ ៗ ដែរ ។

យើងសូមជំរាបមិត្តអ្នកអានថា មិត្ត ម៉ៃ លន់ បានបងក្រងសៀវភៅនេះទាំងមូល រួចស្រេចហើយ ។ បើមិត្តណាចង់ជាវ សូមទាក់ទងផ្ទាល់នឹងមិត្ត ម៉ៃ លន់ ឬ នឹងទីស្នាក់ការ ស.ស.ខ ក៏បាន ។ តទៅនេះ យើងសូមចុះបន្ត ៗ នូវអត្ថបទខាងលើ ។

### សេចក្ដីផ្ដើម : —អ្វីដែលហៅថា " សេដ្ឋកិច្ចនយោបាយ " ?

*គេជាច្រើនយល់ច្រឡំ អត្ថន័យនៃពាក្យថា « នយោបាយសេដ្ឋកិច្ច »* ( politique économique ) *នឹងពាក្យថា « សេដ្ឋកិច្ចនយោបាយ »* ( Economie politique ) ។

ការយល់ច្រឡំនេះ មកពីការប្រែភាសាបារាំងមកជាភាសាខ្មែរ ប្រហាក់ប្រហែលគ្នា ៖ « នយោបាយសេដ្ឋកិច្ច ក៏ដូចជាសេដ្ឋកិច្ចនយោបាយ » គ្រាន់តែដាក់ពាក្យថា « នយោ-បាយ » មុន ឬ ក្រោយពាក្យ « សេដ្ឋកិច្ច » ប៉ុណ្ណោះ ។

ការពិតវិញ ពាក្យទាំងពីរឃ្លានេះ មានអត្ថន័យខុសគ្នាច្រើន ។ ពាក្យថា "នយោបាយសេដ្ឋកិច្ច" ( politique économique ) គឺគោលនយោបាយសំដៅទៅគ្រប់នយោបាយ ឬវិធានការណ៍ដែលគេយកមកអនុវត្ត ដើម្បីឆ្ពោះទៅចាប់យកនូវគោលដៅណាមួយ ក្នុងវិស័យសេដ្ឋកិច្ច (កសិកម្ម - ឧស្សាហកម្ម - ការដឹកនាំ ឬ ការពង្រីកផលិតផលផ្សេងៗ) ។ល។

– ឧទាហរណ៍ ៖ ដើម្បីពង្រីកផលិតផលនៃដំណាំណាមួយ ដូចជាកប្បាសជាដើម

ឬមួយ គេរ៉ាប់រងរកផ្សារសម្រាប់កប្បាសឲ្យបានគ្រប់គ្រាន់

ឬមួយ គេកំណត់តម្លៃកប្បាសឲ្យបានចំណេញដល់ផលិតករ

ឬមួយ គេមិនឲ្យនាំអំបោះកប្បាសចូលមកពីប្រទេសក្រៅ

– ឧទាហរណ៍មួយទៀត ៖ ដើម្បីទប់កុំឲ្យទំនិញឡើងថ្លៃ

ឬមួយ គេកំណត់ថ្លៃទំនិញ ដោយមានការត្រួតពិនិត្យយ៉ាងមធ្យ័ត

ឬមួយ គេទប់មុខទំនិញនោះកុំឲ្យចេញទៅក្រៅ

ឬមួយ គេបញ្ចូលទំនិញពីបរទេស ឲ្យហូរហៀរលើផ្សារជាតិ ។ល។

គេអាចយកឧទាហរណ៍ច្រើនទៀតមកបញ្ជាក់ តែឧទាហរណ៍ ១-២ ខាងលើអាចឲ្យយើងយល់បានដែរ អំពីអត្ថន័យរបស់ពាក្យ "នយោបាយសេដ្ឋកិច្ច" ។

ឯពាក្យថា "សេដ្ឋកិច្ចនយោបាយ – Economie politique" គឺបានន័យថា វិជ្ជាសាស្ត្រសិក្សាអំពីសេដ្ឋកិច្ច – សេដ្ឋកិច្ចវិទ្យា ពោលគឺសិក្សាអំពីការបង្កើតផល អំពីរបៀបបង្កើតផល អំពីការវិវត្តន៍នៃការបង្កើតផល ។ល។

សូមជ្រាបថា មូលដ្ឋាននៃសកម្មភាពខាងសេដ្ឋកិច្ច គឺបិតនៅលើការបង្កើតផល ។ យ៉ាងណាមិញ គេមិនអាចលក់ដូរ ឬ ទិញបានទេ ប្រសិនបើគេមិនបានបង្កើតជាបឋមនូវទំនិញទាំងនោះ ។ ដូច្នេះ ដើម្បីសិក្សានូវគ្រប់ធាតុកូតសេដ្ឋកិច្ច គេត្រូវចាប់សិក្សាជាដំបូងនូវការបង្កើតផលនេះឯង ។

គប្បីជ្រាបថា ដើម្បីផលិតនូវរបស់អ្វីមួយដែលមានប្រយោជន៍ដល់ការរស់នៅ មនុស្សត្រូវពឹងពាក់ទាក់ទងគ្នាជានិច្ច ពុំអាចធ្វើការដាច់តែម្នាក់ឯងឡើយ ទោះបីនៅក្នុងបុរាណសម័យយូរយារណាស់មកហើយក្តី ។ មនុស្សម្នាក់ៗ សុទ្ធតែបានរួបរួមគ្នាក្នុងសង្គមមួយ ហើយមនុស្សម្នាក់ៗ ត្រូវបានទទួលពីសង្គមវិញ នូវការគាំទ្រជាចាំបាច់ ដើម្បីបង្កើតផលិតផលអ្វីមួយដែលខ្លួនត្រូវការ ។ គ្រាន់តែសង្កេតមើលអាណិកជនខ្មែរលើ ក៏អាចយល់បានដែរថា ការរួមដៃគ្នាក្នុងការបរបាញ់ក្តី ក្នុងការនេសាទក្តី ឬក្នុងគ្រប់សកម្មភាពដទៃទៀតក្តី តែងហុចផលប្រសើរជាងកិច្ចការ ដែលគេបានធ្វើតែម្នាក់ឯង ។ ម្យ៉ាងទៀត ការរីកចំរើនខាងបច្ចេកទេស នឹងអាចមានល្បឿន និង សន្ទុះឆាប់រហ័សបាន លុះត្រាតែមានការប្រណាំងប្រជែងគ្នា និងការពឹងពាក់ជួយគ្នាទៅវិញទៅមក ។ ការរីកចំរើនទាំងនេះ ជាហេតុឲ្យមនុស្សយើងរិះរកនូវមធ្យោបាយថ្មីៗ ទៀត ដើម្បីបង្កើតនូវភោគទ្រព្យខាងសម្ភារៈជាចាំបាច់សម្រាប់ជប់លៀងជីវិត ។ ការទាក់ទងគ្នាក្នុងសង្គមដែលគេបានឃើញ មានតាំងពីសង្គមដាន់ដើមមកម្ល៉េះនោះ រឹតតែមានសភាពច្បាស់លាស់ទៅទៀត ក្នុងបច្ចុប្បន្នសម័យនេះ ។ យ៉ាងណាមិញ ក្នុងសង្គមទំនើប គ្រប់កិច្ចការទាំងឡាយសុទ្ធសឹងតែមានបច្ច័យទាក់ទងគ្នាទៅវិញទៅមកជាដរាប ។ ឧទាហរណ៍ : ជាងកាត់ដេរត្រូវការប្រើប្រាស់នូវវត្ថុធាតុដើមដូចជា អំបោះ - ម្ជុល - សំពត់ - កំណាត់ - ឡេវ . . . ។ល។ ដែលមានប្រភពមកពីគ្រប់ទិសទីក្នុងលោក ។

ចំពោះសេដ្ឋកិច្ចវិទ្យា ការទាក់ទងខាងផ្លូវសង្គម មានគ្រឹះឫសកែវក្នុងគ្រប់បំណងទាំងឡាយ ដែលបានចងបុគ្គលមួយទៅបុគ្គលមួយទៀត ក្រុមមួយទៅក្រុមមួយទៀត ប្រជាជាតិមួយទៅប្រជាជាតិមួយទៀត ក្នុងការបង្កើតផលនេះឯង ។

ដូច្នេះ សេដ្ឋកិច្ចនយោបាយ មិនមែនសិក្សាគ្រប់សកម្មភាពសេដ្ឋកិច្ចនៃបុគ្គលម្នាក់ៗឲ្យដាច់ពីគេឯងឡើយ ។ ផ្ទុយទៅវិញ គឺសិក្សានូវបច្ច័យទាក់ទងដែលបានចងបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតក្នុងការបង្កើតផល ដោយគេយល់ថា មនុស្សម្នាក់ៗ ពុំដែលរស់នៅទោលដាច់ពីសង្គមបានឡើយ ព្រោះមនុស្សជាសត្វមួយមានលក្ខណៈជាសង្គម រចនាដោយសង្គម ជាសត្វមួយដែលគ្រប់ទ្រង់ទ្រាយនិងរូបភាពនៃសកម្មភាពរបស់ខ្លួន ជាពិសេសសកម្មភាពខាងសេដ្ឋកិច្ច មានលក្ខណៈមានចារិកជាសង្គម ។ ដូច្នេះ មូលដ្ឋាននៃសេដ្ឋកិច្ចនយោបាយ មិនត្រឹមតែបិតនៅត្រង់ការបង្កើតផលប៉ុណ្ណោះទេ គឺបិតនៅលើបំណងទាំងឡាយដែលបានចងមនុស្សរវាងគ្នានឹងគ្នា ក្នុងការបង្កើតផលថែមទៀត ។

គប្បីកត់សំគាល់ទៀតថា បំណងទាំងនោះ តែងតែមានការផ្លាស់ប្តូរប្រែប្រួលជានិច្ច-និរន្តរ៍ ពុំដែលមានសភាពនឹងនជាអចិន្ត្រៃយឡើយ ។ សេដ្ឋកិច្ចនយោបាយ មានការៈវែកញែកស្រាវជ្រាវរិះរក នូវបុព្វហេតុនិងកម្លាំងទាំងឡាយ ដែលធ្វើឲ្យមានការប្រែប្រួលទាំងនោះ ។

## របៀបបង្កើតផល

ការបង្រៀនសិស្សក៏មានរបៀប ទទួលទានបាយក៏មានរបៀប ការបង្កើតផលក៏មានរបៀប ដូច្នោះដែរ ។

គ្រប់បែបបទដែលមនុស្សយើងប្រើប្រាស់ ដើម្បីផលិតនូវភោគទ្រព្យខាងសម្ភារៈទាំងឡាយ ដូចជាចំណីអាហារ - ស្បែកជើង - សំលៀកបំពាក់ - ផ្ទះសំបែង ឬ ឧបករណ៍សម្រាប់បង្កើតផល ដែលជាចាំបាច់ដល់ជីវភាពនឹងការលូតលាស់នៃសង្គម បែបបទ

ទាំងនេះហៅថា របៀបបង្កើតផលនៃសង្គមនីមួយៗ ។ ការវែកញែកបានឲ្យយើងឃើញថា ក្នុងរបៀបបង្កើតផល គេអាចចែកជាពីរសណ្ឋាន ៖

១– កម្លាំងសម្រាប់បង្កើតផល ឬ កម្លាំងបង្កើតផល

២– ភាពទាក់ទងគ្នា ក្នុងការបង្កើតផល ។

## អ្វីដែលហៅថា កម្លាំងបង្កើតផលរបស់សង្គម ?

កម្លាំងបង្កើតផលក្នុងសង្គមនីមួយៗ ជាបឋមគឺមានឧបករណ៍សម្រាប់បង្កើតផល ដូចជា វត្ថុធាតុដើម - អាគារ - រោងចក្រ - មាស៊ីន ។ល។ តមកទៀត គឺមនុស្សដែលប្រើប្រាស់ ដែលកាន់ម៉ាស៊ីន នឹងឧបករណ៍ទាំងនោះ ដើម្បីបង្កើតផលដូចជា កម្មករ - កសិករ - វិស្វករ ។ល។ គេអាចបញ្ចូលទៅក្នុងកម្លាំងបង្កើតផល នូវបញ្ញារបស់មនុស្សទៀតផង ពីព្រោះដើម្បីបង្កើតផល គេត្រូវមានចំណេះវិជ្ជា មានការពិសោធន៍ មានទំលាប់ក្នុងការងារ របស់គេ ។ សរុបទៅ កម្លាំងបង្កើតផលមាន ៖

– ឧបករណ៍សំរាប់បង្កើតផល

– មនុស្សនឹងការពិសោធន៍របស់គេក្នុងការបង្កើតផល ។

គប្បីកត់សំគាល់ថា កម្លាំងបង្កើតផលនេះជាទិដ្ឋភាពមួយនៃរបៀបបង្កើតផល ជាទិដ្ឋភាពដែលបង្ហាញឲ្យយើងឃើញអាកប្បកិរិយា និង ឥរិយាបថរបស់មនុស្ស ចំពោះឧបករណ៍នឹងកម្លាំងធម្មជាតិដែលមនុស្សយើងប្រើប្រាស់ ដើម្បីផលិតនូវសម្ភារៈនឹងភោគទ្រព្យទាំងឡាយ ។ ឯទិដ្ឋភាពមួយទៀត ដែលជាទិដ្ឋភាពសំខាន់ជាងគេនោះ គឺការទាក់ទងរវាងមនុស្សនឹងមនុស្សក្នុងការបង្កើតផល ។ ឧទាហរណ៍ ៖ ក្នុងការតស៊ូយ៉ាងស្វិតស្វាញតទល់នឹងធម្មជាតិ ដើម្បីបង្កើតភោគទ្រព្យខាងសម្ភារៈ មនុស្សយើងមិនមែននៅដាច់ៗពីគ្នាឡើយ មិនមែនធ្វើដាច់ពីគ្នា ឯនេះម្នាក់ ឯនោះម្នាក់ទេ ។ ផ្ទុយមកវិញ គេផ្គុំគ្នា

គេរួបរួមជាក្រុម ជាពួក ដើម្បីបង្កើតផលទាំងនោះ ។ ដូច្នេះហើយបានជាការបង្កើតផល ទោះឋិតនៅក្នុងលក្ខណៈណាក៏ដោយ ក៏មានសភាព មានលក្ខណ ជាសង្គមជានិច្ចនិរន្តរ៍ ។

សញ្ញាណសំខាន់ដែលគប្បីកត់ត្រាទុកក្នុងការបង្កើតផល គឺមនុស្សនេះឯង ដែលជាផលិតករ និងការទាក់ទងខាងផ្លូវសង្គម រវាងបុគ្គលនិងបុគ្គលក្នុងការអនុវត្តន៍នូវកិច្ចការនេះ ។

គេអាចសួរថា តើការទាក់ទងនោះ បំណងទាំងនោះ ដែលចងបុគ្គលមួយទៅបុគ្គលមួយទៀត ក្នុងការបង្កើតផលមានសភាពយ៉ាងណាខ្លះទៅ ? ការទាក់ទងទាំងនេះ មានលក្ខណៈប្លែកៗគ្នា :

— មនុស្សនឹងមនុស្សអាចរួបរួមប្រមូលគ្នា ដោយសុខចិត្តស្មើភាពគ្នា ដើម្បីប្រកបកិច្ចការណាមួយ ដូចជាសង់ផ្ទះ ជីកអណ្តូង ធ្វើស្រែយកវេនគ្នា ។ល។

ក៏ប៉ុន្តែ បើបុគ្គលណាម្នាក់មានមធ្យោបាយបង្កើតផល ហើយបានបង្ខំបុគ្គលដទៃទៀត ដោយវិធីណាក៏ដោយ ដើម្បីឲ្យអ្នកនោះធ្វើការឲ្យខ្លួន ដោយប្រើប្រាស់នូវឧបករណ៍ទាំងនោះ ការទាក់ទងក្នុងការបង្កើតផលរបៀបនេះ បានន័យថា ជាការទាក់ទងក្នុងការបង្ខំ ។

ដោយសង្ខេប គេអាចសន្និដ្ឋានបានថា ការទាក់ទងគ្នាក្នុងការបង្កើតផល អាចមានសភាពដូចខាងក្រោមនេះ :

— ឬមួយជាសហប្រតិបត្តិការ ជាការជួយគ្នាទៅវិញទៅមក ។ ក្នុងករណីនេះ បុគ្គលនិងបុគ្គលមានភាពស្មើគ្នា ។

— ឬមួយជាការចុះកិច្ចសន្យាទទួលធ្វើ ។ ក្នុងករណីនេះ គឺមានម្ចាស់ ( ថៅកែ ) និងខ្ញុំ ឬ កម្មករ ។

ដូច្នេះ របៀបបង្កើតផលក្នុងគ្រប់សង្គមមនុស្ស អាចចែកចេញជាវត្ថុធាតុពីរដែលជាប់នឹងគ្នា ហើយដែលអាចក្លាយទៅជាផ្ទុយនឹងគ្នា ប្រឆាំងនឹងគ្នាវិញក៏សឹងមាន ពោលគឺ :

ម្ខាងមានកម្លាំងឬមធ្យោបាយសំរាប់បង្កើតផលរបស់សង្គម ម្ខាងទៀតគឺការទាក់ទងរវាងមនុស្សនិងមនុស្សក្នុងការបង្កើតផល ។ ឧទាហរណ៍ : ក្នុងសង្គមមូលធននិយម មូលដ្ឋានសំខាន់ គឺឋិតនៅត្រង់មធ្យោបាយសំរាប់បង្កើតផល ដែលជាកម្មសិទ្ធិឯកជននៃមនុស្សម្នាក់ ឬមួយក្រុមតូច ៗ ឯសមាជិកឯទៀតក្នុងសង្គម ដែលគ្មានមធ្យោបាយបង្កើតផលទេនោះ ត្រូវលក់កម្លាំង ស៊ីឈ្នួលអ្នកដទៃ ដើម្បីទទួលកំរៃយកមកចិញ្ចឹមជីវិត ។

បើយើងពិនិត្យឲ្យជ្រាលជ្រៅទៅទៀតក្នុងក្របខ័ណ្ឌនេះ ដែលធម្មតាមនុស្សយើងត្រូវមានសមភាពនៅចំពោះមុខច្បាប់ កម្លាំងបង្កើតផល ចេះតែលូតលាស់ធំឡើងជាដរាប (ចំពោះកម្មករចេះតែកើនស្របទៅតាមនោះដែរ - គ្រឿងបច្ចេកទេសរឹតតែល្អឡើង ឯទំនិញសោត ក៏ត្រូវផលិតបានយ៉ាងសំបូណ៌ ) ។ តែដល់ពេលណាមួយកម្លាំងបង្កើតផលនេះប្រែទៅជាមានសភាព និង ទំហំខ្លាំងលើសលុប នៅពេលនោះហើយ ទំនាស់រវាងកម្លាំងបង្កើតផលនិងរបៀបបង្កើតផល ក៏កើតមានឡើងទៅតាមនោះដែរ ។ ដើម្បីចៀសឲ្យផុតនូវទំនាស់ទាំងនោះ ការផ្លាស់ប្តូរនូវរបៀបបង្កើតផលសម័យចាស់ ត្រូវតែបានផ្លាស់ជារបៀបបង្កើតផលថ្មីមួយទៀត ពោលគឺក្នុងឧទាហរណ៍ដែលយើងយកមកអធិប្បាយខាងលើ របៀបបង្កើតតាមមូលធននិយម ត្រូវតែផ្លាស់ទៅជារបៀបបង្កើតផលតាមសង្គមនិយម ។

ប្រវត្តិនៃបាតុភូតសេដ្ឋកិច្ចបានបង្អុលប្រាប់យើងថា របៀបបង្កើតផលមានការវិវត្តន៍ជានិច្ច ហើយការវិវត្តន៍នោះ ត្រូវប្រព្រឹត្តទៅតាមច្បាប់ទូទៅដូចខាងក្រោមនេះ :

កម្លាំងបង្កើតផលផ្លាស់ប្តូរមុនគេបង្អស់ ក្រោយមកទៀតទើបរបៀបបង្កើតផល ។ ក្រោយពីមានការប្រែប្រួលផ្លាស់ប្តូរខ្លួនឯងរួចហើយ ត្រូវបង្ខំឲ្យរបៀបទាក់ទងក្នុងការបង្កើតផលផ្លាស់ប្រែទៅតាមខ្លួនដែរ ។

ចំពោះឧបករណ៍ខាងលើ ដែលយើងយកមកអធិប្បាយក្នុងសង្គមមូលធននិយមនេះ វាមានសភាពទូទៅ មិនថាសង្គមណាជាសង្គមណាឡើយ ។

បើយើងពិនិត្យឲ្យហ្មត់ចត់ទៅទៀត ឃើញថា កាលសម័យសង្គមសក្តិភូមិ ការទាក់ទងរវាងគ្នានឹងគ្នា ការបង្កើតផល របៀបបង្កើតផលបានប្រែទៅជាឧបករណ៍មួយនៃការរីកចំរើន នៃកម្លាំងបង្កើតផល ដែលមានដំហានលូតលាស់ឆាប់រហ័សដោយសារស្នាដៃនៃសិប្បករ ឬម្ចាស់មូលធនិកកម្មន្តសាល ។ ពួកគហបតីទាមទារនូវសេរីភាពខាងការដំឡើងសហគ្រាស គេស្រែកជំទាស់ប្រឆាំងនឹងបទបញ្ជានៃសាជីវកម្ម ប្រឆាំងនឹងឧបសគ្គចរាចរណ៍នៃទំនិញ ប្រឆាំងនឹងសង្គមឯកសិទ្ធិនៃវណ្ណៈដឹកនាំរដ្ឋ ។ លទ្ធផលទាំងនេះ បានបណ្តាលឲ្យមានការប្រែប្រួលយ៉ាងសំបើម គឺបដិវត្តន៍គហបតីបារាំងកាលពីឆ្នាំ ១៧៨៩ ដែលបានធ្វើឲ្យប្រែប្រួលដល់ឫសកែវនូវរបៀបបង្កើតផលក្នុងសម័យនោះ ។

កំណត់សំគាល់ : ទំនាស់ធំបំផុតក្នុងមូលធននិយម គឺទំនាស់រវាងកម្មសិទ្ធិឯកជននៃមធ្យោបាយទាំងឡាយសំរាប់បង្កើតផល និងលក្ខណៈជាសង្គមនៃការបង្កើតផល ។ ទំនាស់នេះមានជានិច្ចនៅក្នុងសង្គមមូលធន ដែលគេមិនអាចចៀសវាងបានឡើយ ។ ឯក្នុងសង្គមនិយមវិញ គេដោះស្រាយទំនាស់ខាងលើនេះ ដោយធ្វើឲ្យមធ្យោបាយសំរាប់បង្កើតផលទាំងឡាយ ក្លាយទៅជាសម្បត្តិរួមរបស់សង្គម គឺមិនមែនសម្បត្តិឯកជនឡើយ ។ ក្នុងពេលនោះ បុគ្គលទាំងឡាយ ដែលជាម្ចាស់នៃមធ្យោបាយសំរាប់បង្កើតផលរបស់ខ្លួន អាចបញ្ចូល គ្រប់ពេលវេលា នូវការផ្លាស់ប្តូរជាចាំបាច់ ដើម្បីរក្សាតុល្យភាព រវាងកម្លាំងបង្កើតផល និងរបៀបបង្កើតផល ។

តាមរបៀបបង្កើតផល តាមការទាក់ទងរវាងមនុស្សនឹងមនុស្ស ក្នុងការបង្កើតផលដែលបានលូតលាស់ តាំងពីបុរាណសម័យមកដល់បច្ចុប្បន្នកាលនេះ គេអាចស្រង់បាននូវរបៀបបង្កើតផល ៥ បែប ដែលយើងឲ្យឈ្មោះថា : សហគមបុរាណ - ទាសសង្គម - សក្តិភូមិសង្គម - មូលធនសង្គម និង សង្គមនិយម ។

# I- សហគមបុរាណសម័យ

ការសិក្សាសេដ្ឋកិច្ចដំនាន់ដើមជាការចាំបាច់ ដើម្បីត្រោះទៅយល់នូវការវិវត្តន៍នៃបាតុភូតខាងសេដ្ឋកិច្ចដ៏ស្មុគស្មាញ ដែលបានលេចឡើងរៀងដរាបរហូតមកទល់នឹងសព្វថ្ងៃនេះ ។

បើគេត្រឡប់មើលទៅអតីតកាលដ៏យូរយារណាស់មកហើយ គេនឹងឃើញថាមនុស្សយើងតាំងពីចាប់កំណើតមក បានប្រមូលផ្តុំគ្នារស់នៅជាសង្គម ។ ការណ៍នេះរឹតតែច្បាស់ទៅទៀត បើយើងមើលការរស់នៅរបស់ខ្មែរលើ របស់ពួកស្បែកខ្មៅនៅទ្វីបអាហ្វ្រិក របស់ពួកបណ្តាជនភាគខ្លះ នៅអូស្ត្រាលី នៅប៉ូលីណេស៊ី . . . ។ តាមលំដាប់ជីវភាពតាមរបៀបរស់នៅ គេចែកជា ៣ លំដាប់ ដូចតទៅ :

១– របៀបរស់នៅជាមនុស្សព្រៃ

២– របៀបរស់នៅក្នុងអនារ្យធម៌សម័យ

៣ – របៀបរស់នៅក្នុងអារ្យធម៌សម័យ

តែក្រោយមកទៀត ការចែករបៀបខាងលើនេះត្រូវបានលះបង់ចោល ហើយអ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រ បានយករបៀបថ្មីមកប្រើ ដោយផ្អែកទៅលើឧស្សាហកម្ម គឺ :

១– យុគឧស្សាហកម្មថ្មបិត : ក្នុងពេលនោះ មនុស្សយើងយកថ្មទាំងដុលមកវាយបំបែក ដើម្បីធ្វើជាឧបករណ៍សម្រាប់បង្កើតផល ដូចជា ធ្វើផ្ទៃសន្ទូច ធ្វើព្រួញ ធ្វើពូថៅ . . . ។

២– យុគឧស្សាហកម្មថ្មសំលៀង : ក្រោយមកទៀត មនុស្សយើងមិនគ្រាន់តែបេះបិតថ្ម បេះបំបែកថ្ម ប៉ុណ្ណោះទេ គឺថែមទាំងបេះបំបែក-បិត ហើយយកថ្មនោះទៅសំលៀងថែមទៀត ។ ការបេះសំលៀងថ្មនេះ ជាការចំរើនមួយយ៉ាងសំខាន់ក្នុងការរស់នៅរបស់គេ ។ ថ្មសំលៀងមានមុខមុតប្រើបានពូកែសក្តិសិទ្ធិ ក្នុងមុខរបររបស់គេ ។

៣– យុគឧស្សាហកម្មលោហធាតុ ៖ នៅពេលក្រោយជាយូរមកទៀត មនុស្សយើងចេះប្រើលោហធាតុ ដើម្បីយកទៅធ្វើឧបករណ៍ប្រើប្រាស់ ដូចជា កាំបិត ពូថៅ ស្ទូ ម្ដ អាវុធ ដើម្បីការពារខ្លួន ។ ការប្រើប្រាស់លោហធាតុនេះ ជាដំហានក្រោយបង្អស់ នៃវឌ្ឍនធម៌របស់មនុស្សយើង ។ យុគឧស្សាហកម្មលោហធាតុនេះ មានប្រមាណជាបួនពាន់ឆ្នាំមុន គ.ស តែការចេះប្រើប្រាស់លោហធាតុមិនមែនប្រព្រឹត្តទៅក្នុងពេលជាមួយគ្នា គ្រប់បណ្ដាជនសម័យនោះទេ ។ ខ្លះបានស្គាល់មុនគេ ខ្លះក្រោយគេតាមលំដាប់ ពីព្រោះការផ្សាយការរកឃើញខាងបច្ចេកទេសទាំងនោះ មិនអាចប្រព្រឹត្តទៅបានដោយស្រួលឡើយ ។ ដូច្នេះ គេមិនអាចសន្និដ្ឋានបានថា ការវិវត្តន៍នៃសង្គមជំនាន់ដើមបានប្រព្រឹត្តទៅស្មើគ្នាគ្រប់ទីកន្លែងដោយទៀងទាត់បានឡើយ ។

## ក– ទ្រង់ទ្រាយសង្គមជំនាន់ដើម ៖ ប័ក្សសម្ពន្ធ

ចូរកត់សំគាល់ថា ធាតុកូតសេដ្ឋកិច្ចនិងខាងសង្គម មានបច្ច័យទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ។ យ៉ាងណាមិញ សណ្ឋានសង្គម (Structure sociale) គ្រាន់តែជាស្រមោលនៃលក្ខណៈសេដ្ឋកិច្ចរបស់សង្គមនីមួយ ៗ ប៉ុណ្ណោះ ។ បើនិយាយឲ្យងាយយល់ សង្គមទុកដូចជាតួផ្ទះខាងលើ ឯលក្ខណៈសេដ្ឋកិច្ច ជាគ្រឹះខាងក្រោម ។ លក្ខណៈគ្រឹះយ៉ាងណា តួផ្ទះខាងលើក៏យ៉ាងដូច្នោះដែរ បានន័យថា លក្ខណៈសេដ្ឋកិច្ចយ៉ាងណា សង្គមក៏មានទ្រង់ទ្រាយ មានរូបភាព មានសណ្ឋានទៅតាមលក្ខណៈនោះដែរ ។

គ្រប់សង្គមជំនាន់ដើម ដែលគេបានស្គាល់ សុទ្ធតែបែកជាប័ក្សសម្ពន្ធ ។ ប័ក្សសម្ពន្ធនីមួយ ៗ មានគ្រួសារមួយចំនួនតិច-ច្រើនតាមលំដាប់ តាមទីកន្លែង ។ ដូច្នេះ គេចាត់ទុកគ្រួសារនិងប័ក្សសម្ពន្ធជាទ្រង់ទ្រាយពីរជាសារវ័ន្ត ជាគ្រឹះរបស់សង្គមដែលបានរួមរស់នៅជាមួយគ្នា ។

គ្រួសារជាក្រុមសង្គមមួយមានឪពុកម្ដាយនិងកូន ។ គេបានប្រទះនូវទ្រង់ទ្រាយគ្រប់បែបគ្រប់យ៉ាងនៃគ្រួសារ ។ តាមធម្មតា គ្រួសារមានប្ដី ឬ មានប្រពន្ធតែមួយ ( Famille monogame ) តែគេអាចប្រទះឃើញនូវគ្រួសារខ្លះមានប្ដីច្រើនគ្នា ហើយមានប្រពន្ធតែម្នាក់ ឬក៏ប្រពន្ធច្រើននាក់ ហើយមានប្ដីតែម្នាក់ ។

ក្នុងគ្រួសារនីមួយៗ គេសុទ្ធតែបានបែកការងារគ្នាដាច់មុខ ។ ក្នុងគ្រួសារអ្នកបរបាញ់ ប្ដីត្រូវទៅព្រៃរកបាញ់សត្វ ប្រពន្ធត្រូវទៅជីកដំឡូងព្រៃ កាយឫសឈើ ។ល។

ក្នុងគ្រួសារកសិករ ប្រុសៗ កាប់គាស់ព្រៃឈើ ស្រីៗ ដាំដំណាំ ហើយនឹងគិតគូរខាងស្ទូងដណ្ដាំ ។ ម្យ៉ាងទៀត ការផ្សាំងសត្វជាកិច្ចដាច់មុខរបស់ប្រុស ឯការដំបាញវិញ វាជាកិច្ចការរបស់ស្រី ។ ការបង្កើតគ្រួសារ គឺធ្វើឡើងដោយអាពាហ៍ពិពាហ៍ ដែលអនុលោមទៅតាមរបៀបផ្សេងៗ ។ តាមធម្មតា គេទិញស្រីយកមកធ្វើប្រពន្ធ ឯថ្លៃឡើងចុះតាមធនធានខាងស្រី តាមទីកន្លែង ។

សមាជិកនៃបក្សសម្ពន្ធនីមួយៗ មានចំណងទាក់ទងគ្នានឹងគ្នាយ៉ាងជ្រាលជ្រៅ ដូចជា: ចំណងខាងជំនឿនូវដូនតាជាមួយគ្នា ឬ គោរពចំពោះតូតឹម ( Totem ) ដូចគ្នា (សត្វដែលជាដើមសន្តតិវង្ស ) ។ ប៉ុន្ដែការប្រមូលផ្ដុំគ្រួសារជាប័ក្សសម្ពន្ធនេះ គឺគេសំអាងទៅលើមូលដ្ឋានសេដ្ឋកិច្ចជាអាទិ ។ ប័ក្សសម្ពន្ធជាសណ្ឋានមួយចាំបាច់ ដើម្បីប្រមូលផ្ដុំកម្លាំងគ្នាក្នុងការបរបាញ់ក្ដី ក្នុងកសិកម្មក្ដី ។ ទាំងនេះគឺដើម្បីប្រកួតប្រណាំង ប្រជែងនឹងប័ក្សសម្ពន្ធជាបច្ចាមិត្រ ។

តាមធម្មតា សមាជិកនៃប័ក្សសម្ពន្ធត្រូវតែចេញទៅរកប្ដី ឬ រកប្រពន្ធក្រៅពីប័ក្សសម្ពន្ធរបស់ខ្លួន ។ តែក្នុងប័ក្សសម្ពន្ធខ្លះ អាពាហ៍ពិពាហ៍រវាងប្រុស នឹង ស្រីគ្នាឯង មានសភាពជាកាតព្វកិច្ចទៀតផង គឺគេបង្ខំឲ្យក្រមុំកម្លោះក្នុងប័ក្សសម្ពន្ធជាមួយគ្នា រៀបអាពាហ៍ពិពាហ៍ជាប្ដីប្រពន្ធ ។

ចូរកត់សំគាល់ទៀតថា បក្សសម្ពន្ធនិមួយៗ មានសភាពពបស្មើ មានសាមគ្គីធម៌រឹងប៉ឹងណាស់ ។ រួមសំបាច់និយមបុកណាបានចាប់កំណើតឡើងក្នុងផ្ទៃបក្សសម្ពន្ធនេះឯង ។ យើងនឹងបរិយាយជាខាងក្រោយ នូវទិដ្ឋភាពសេដ្ឋកិច្ចរបស់បក្សសម្ពន្ធនេះ ។

តាមធម្មតា គេយកសត្វមកធ្វើជាទីសក្ការៈបូជា ជាតូតឹម (Totem) (សត្វដើមសន្តតិវង្ស) ។ ជួនកាលគេយកដើមឈើជាតិអ្វីមួយ ឬកម្លាំងធម្មជាតិណាមួយ មកធ្វើជាតូតឹមនេះឯង ។ ឯឈ្មោះបក្សសម្ពន្ធទាំងនោះ គឺយកឈ្មោះតូតឹមមកជាសញ្ញាសំគាល់ ។ បក្សសម្ពន្ធត្រូវថែរក្សានូវចំណងទាក់ទងជាញាតិសាច់សាលោហិតយ៉ាងជិតស្និទ្ធជាមួយនឹងតូតឹម ។ យើងកត់សំគាល់បានទៀតថា ការជឿនូវតូតឹមមានជួបប្រទះនៅគ្រប់តែលើទ្វីបទាំងអស់ ។

កាលដើមកំណើតឡើយ បក្សសម្ពន្ធដំបូង គឺនិយមទៅតាមខាងម្ដាយ ពោលគឺគេទទួលស្គាល់តែពូជពង្សខាងម្ដាយ ( clan matrimonial ) ។ គេអាចសន្និដ្ឋានបានថា ក្នុងសង្គមជាន់ដើម ស្រីៗ មានមុខងារធំជាងប្រុសទៅទៀត ។ ឯឥទ្ធិភាពនៃបុរសជាព្រឹត្តិការណ៍ថ្មីៗ ជាខាងក្រោយវិញទេ ។

## ខ– សេដ្ឋកិច្ចជំនាន់ដើម

ក្នុងសង្គមដំបូងបង្អស់ដែលគេបានស្គាល់ មនុស្សយើងប្រកបជីវភាពដោយបរបាញ់ ដោយនេសាទ ឬដោយបេះផ្លែផលានុផល ។ បច្ចេកទេសជាសារវន្តនៅពេលនោះ គឺការស្គាល់ភ្លើង ។ ឧបករណ៍ផ្សេងៗ សម្រាប់ប្រើប្រាស់សុទ្ធតែធ្វើអំពីថ្ម ដូចជាលំពែង ដុំដៃ ឬព្រួញ ។ ការបេះប្រើស្នាទឹងព្រួញ ជាការចំរើនមួយយ៉ាងធំនៅពេលនោះ ។ គេអាចប្រដូច ស្នា ព្រួញ នៅពេលនោះ ទៅនឹងលំពែងក្នុងសម័យអនារ្យធម៌ ឬនឹងកាំភ្លើងក្នុងសម័យអារ្យធម៌ ។

ក្នុងសម័យនោះ ស្រី ៗ ក្រៅពីកិច្ចការផ្សេង ៗ ក្នុងផ្ទះ មានចេះដាំដំណាំបន្តិចបន្តួច ដូចជា ដើមរុក្ខជាតិផ្សេង ៗ ដើម្បីការត្រូវការក្នុងគ្រួសារ ។ ក្នុងសម័យជាមួយគ្នានេះ គេឃើញមានចានឆ្នាំងដែរ ។ ការចេះធ្វើចាន ឆ្នាំង ក្អមនេះ ជាការចំរើនមួយយ៉ាងសំខាន់ ខាងបច្ចេកទេស ព្រោះគេមានលទ្ធភាពនឹងថែរក្សាទុកបានយូរនូវចំណីចំណុកផ្សេង ៗ ។ ក្រៅពីការធ្វើ ស្នា ព្រួញ គេមានចេះធ្វើពូថៅ រណារ រនាស់ អំពីថ្មសំលៀង ។ ក្រោយបន្តិចមកទៀត កណ្ដៀវថ្មក៏បានលេចចេញមកដែរ ។ ឯនេសាទុបករណ៍វិញ ភាពចំរើនចេះតែបានប្រសើរម្ដងបន្តិច ៗ រៀងដរាបមក ។

ក្នុងសង្គមជាន់ដើមនោះ របបកម្មសិទ្ធិមានពីរយ៉ាង :

– ឧបករណ៍បង្កើតផល ដូចជា គ្រឿងអាវុធ ពូថៅ លំពែង (ចំពោះប្រុស) ឆ្នាំង ចានក្បាន ឬប្រដាប់ប្រដាក្នុងផ្ទះ ( ចំពោះស្ត្រី ) ទាំងអស់នេះ ជាកម្មសិទ្ធិរបស់ជនម្នាក់ៗ ( ជាកម្មសិទ្ធិឯកជន ) ។

– ឯដំបន់ប្រមាញ់ លទ្ធផលនៃការបរបាញ់ជាកម្មសិទ្ធិរបស់ប៉ក្សពួកសម្ពន្ធទាំងមូល ( ជាកម្មសិទ្ធិរួម ) ។

ម្យ៉ាងទៀត ក្នុងសម័យនោះ គេឃើញមានរបៀបចែកការងារគ្នាតាមភេទផង តាមអាយុផង ពោលគឺ តាមសមត្ថភាពនៃមនុស្ស ។ ប្រុសៗច្រើនធ្វើការធ្ងន់ ដូចជា : នេសាទ បរបាញ់ ធ្វើសាស្ត្រាវុធ ឬ ឃ្វាលសត្វ ។ ឯស្រី ៗវិញ ច្រើនតែប្រកបការស្រាលៗ ដូចជា : ការថែរក្សានិងអប់រំកូន - កិច្ចការទាំងឡាយក្នុងផ្ទះ បោសសំអាត ដាំដំណាំ ស្ទូញ ឬ ដេរប៉ាក់ ។ល។ ការងារមិនមែនតែប្រព្រឹត្តក្នុងក្របខណ្ឌគ្រួសារប៉ុណ្ណោះទេ ។ ប៉ក្សសម្ពន្ធនីមួយ ៗ មានការងារផ្សេងៗពីគ្នា ។ ប៉ក្សសម្ពន្ធខ្លះធ្វើនេះ ប៉ក្សសម្ពន្ធខ្លះធ្វើនោះ ។ ផលិតផលនៃប៉ក្សសម្ពន្ធទាំងនេះ ជាមូលដ្ឋាននៃការដូរគ្នាទៅវិញទៅមក រវាងប៉ក្សសម្ពន្ធទាំងឡាយក្នុងកុលសម្ពន្ធ ( Tribu ) ។ ប្រកត់សំគាល់ទៀតថា នៅសម័យនោះ

គេពុំទាន់ឃើញផ្សារលក់ដូរអ្វីជាត្រឹមត្រូវពេញលក្ខណៈឡើយ ។ ឯការលក់ដូរទំនិញអំបាលមាន ជាកិច្ចរបស់នាយមេហ្វាយរបស់ប័ក្សសម្ពន្ធ ។ ក្នុងឱកាសធ្វើការប្តូរផលិតផលម្តងៗ គេឃើញមានការជប់លៀងយ៉ាងអធិកអធម ។

## គ– ការផ្សាំងសត្វ

ព្រឹត្តិការណ៍សំខាន់ក្នុងសម័យជាន់ដើម គឺការចេះផ្សាំងសត្វ ។ គេអាចស្មានបានថា ក្នុងចំណោមសត្វទាំងឡាយដែលគេចាប់យកមកផ្សាំង គឺសត្វឆ្កែនេះឯង ដែលបានផ្សាំងមុនគេដើម្បីជួយក្នុងការបរបាញ់ ។ តែសំខាន់បំផុត គឺការផ្សាំងសត្វពាហនៈ ហើយនឹងការបង្កើតហ្វូងសត្វ ។ ការចិញ្ចឹមសត្វទាំងនេះ អាចផ្តល់ចំណីអាហារជាទីសុខសាន្តដល់ប័ក្សសម្ពន្ធ ។

ប័ក្សសម្ពន្ធណា ដែលចេះចិញ្ចឹមសត្វមុនគេ ត្រូវចាកចេញពីប័ក្សសម្ពន្ធឯទៀត ។ តាំងពីពេលនោះមក លក្ខណៈនៃការដូរទៀងទាត់ ក៏កើតមានឡើងរវាងប័ក្សសម្ពន្ធកសិកម្មនឹងប័ក្សសម្ពន្ធចិញ្ចឹមសត្វ ។ ក្នុងរយៈពេលជាមួយគ្នា គេត្រូវរិះរករូបិយវត្ថុសំរាប់ធ្វើជាស្ពក្នុងការដូរ ។ ក្បាលសត្វក៏ត្រូវបានយកមកប្រើក្នុងកិច្ចការនេះ ទុកដូចជារូបិយវត្ថុ ។

ភាពខ្លាំងពូកែនៃប័ក្សសម្ពន្ធចិញ្ចឹមសត្វលើប័ក្សសម្ពន្ធឯទៀត ។ មានជំហាររឹងប៉ឹងឆាប់រហ័សណាស់ ។ ម្យ៉ាងទៀត ការចិញ្ចឹមសត្វបានពង្រឹងសកម្មភាពកសិកម្ម ព្រោះគេត្រូវការស្មៅឲ្យសត្វស៊ី ហើយសត្វពាហនៈអាចឲ្យគេប្រើប្រាស់នូវមធ្យោបាយបង្កើតផលមួយថ្មី ហើយដែលមានសារៈសំខាន់ផងគឺ នង្គ័លនេះឯង ។

ចូរកត់សំគាល់ថា ការលូតលាស់ដុះដាលនៃហ្វូងសត្វបណ្តាលឲ្យប័ក្សសម្ពន្ធនេះ ដើរស្វែងរកតំបន់ស្មៅដើម្បីជាចំណីសត្វរបស់ខ្លួន ។ ដូចនេះហើយ ការប្រទូសរាយរវាងប័ក្សសម្ពន្ធចិញ្ចឹមសត្វ នឹងប័ក្សសម្ពន្ធឯទៀត ដែលខ្លួនចង់ដណ្តើមយកកន្លែងតំបន់

ស្មោនោះ បេះតែកើតឡើងញឹកញាប់ ៗ តាមធម្មតា ប័ក្សសម្ពន្ធគន្លាលច្រើនជាអ្នកក្លាហាន ខ្លាំងពូកែជាងបណ្ដាជននិសិទ្ធ មិនសូវផ្លាស់ទីកន្លែង ។

តាមផ្លូវសង្គម ការបេះផ្កាំងសត្វជាបពង្ស័យមួយដ៏ធំរបស់នៃស្រីគេទ ហើយគឺជាជំហានដំបូងនៃឯតទគ្គភាពរបស់បុរស ។ ដំបូង គេទុកស្រីគេទជាធំ ហើយគុងការតពូជពង្សវង្សត្រកូល គេស្គាល់តែខាងម្ដាយ ។ ឥឡូវ ស្រីគេទត្រូវធ្លាក់ចុះទៅក្នុងភាពដុនដាបក្លាយទៅជាឧបករណ៍សម្រាប់តែការត្រេកត្រអាលរបស់បុរស គឺឧបករណ៍សម្រាប់តែបង្កើតកូនទៅវិញ ។ មូលដ្ឋាន ដែលបានបណ្ដាលឲ្យក្រឡាប់ស្ថានភាពបែបនេះ គឺមកពីចាប់តាំងពីការផ្កាំងសត្វ ស្ថានភាពសេដ្ឋកិច្ចខាងប្រុស មានប្រៀបជាងខាងស្រី ។ ប្រុសមិនត្រឹមតែជាម្ចាស់នៃឧបករណ៍ប្រមាញ់ប៉ុណ្ណោះទេ គេថែមជាម្ចាស់នៃឧបករណ៍ថ្មីមួយទៀតគឺសត្វពាហនៈនេះឯង ។ ចាប់តាំងពីពេលនោះមក សិទ្ធិពូជពង្សក៏ធ្លាក់ទៅខាងប្រុសវិញ ។

## ឃ– កំណើតនៃទាសភាព

ការចិញ្ចឹមសត្វហើយនឹងភាពរីកចំរើនខាងកសិកម្ម បានធ្វើឲ្យកម្លាំងបង្កើតផលរឹតតែកើនឡើងជាលំដាប់ទៅតាមនោះដែរ ។ កិច្ចការងាររបស់មនុស្សយើង អាចបង្កើតផលមិនត្រឹមតែគ្រប់គ្រាន់ទេ ថែមទាំងមានសល់ខ្លះទៀតផង ។ ការប្រើកម្លាំងបង្កើតផលថែមជាការចាំបាច់ ឯកម្លាំងទាំងនេះគឺពួកទាសករ “ខ្ញុំកញ្ជះគេ„ ។

ប៉ុរកត់សំគាល់ថា កាលពីដើម ពួកឈ្លើយសង្គ្រាមសុទ្ធតែជាអ្នកឥតមានប្រយោជន៍អ្វីសោះទេ ពីព្រោះកិច្ចការងាររបស់អ្នកអស់នោះ មិនបានផលគ្រប់គ្រាន់នឹងចិញ្ចឹមពោះខ្លួនឯង ។ តែដល់ក្រោយមក ដោយយល់ឃើញថា ការងាររបស់ឈ្លើយទាំងនោះអាចបង្កើតធនធានដល់សង្គម គេក៏ប្រើកម្លាំងនោះក្នុងការបង្កើតផល ។ ដូច្នេះហើយបានជាទាសភាពមានកំណើតឡើង ហើយការផ្លាស់ប្ដូរយ៉ាងទូលំទូលាយបានប្រព្រឹត្តក្នុងលក្ខណៈនៃការបង្កើតផលដែរ ។

## ង– អារ្យធម៌លោហធាតុ

ឧស្សាហកម្មលោហធាតុមានកំណើត ចាប់តាំងពីមនុស្សយើងមានលទ្ធភាពក្នុងការរំលាយលោហធាតុ ។ លោហធាតុដុលមិនអាចយកទៅប្រើប្រាស់អ្វីបានពូកែសក្តិសិទ្ធិឡើយ ។

ដំបូងបង្អស់ គេចេះរំលាយស្ពាន់និងសំណប៉ាហាំងបានជាទង់ដែង យកទៅធ្វើឧបករណ៍ផ្សេងៗ បានរឹងហើយជាប់ផង ។ បន្ទាប់មកទៀត ទើបទេស្គាល់ដែក ។ ចាប់តាំងពីពេលនោះមក មនុស្សយើងអាចធ្វើបានឧបករណ៍ប្លែកៗ ហើយពូកែសក្តិសិទ្ធទៀតផង ដូចជា ពូថៅ ផាល នង្គ័លដែលអាចឲ្យគេកាប់ឆ្ការព្រៃ និង ដាំដំណាំបានឆាយៗ ម្យ៉ាងទៀត លោហធាតុទាំងនោះ អាចឲ្យមនុស្សយើងធ្វើជាគ្រឿងសាស្ត្រាវុធផ្សេងៗច្រើន ហើយមានប្រសិទ្ធភាពទៀតផង ។ នេះជាកត្តានៃឯតទត្តភាពបក្សសម្ពន្ធណា ដែលចេះគេឃើញ និង ប្រើប្រាស់មុនគេនូវបច្ចេកទេសថ្មីនេះ ។

តពីក្រុមសង្គមតូចនេះមក ( បក្សសម្ពន្ធ ) សង្គមមួយធំទូលាយទៀត ក៏បានចាប់កំណើតឡើង គឺអាណាចក្រ ( empires ) ។ ដោយសារដែក គេអាចបង្កើតឧបករណ៍ថ្មីៗ ហើយទំនើបៗទៀតផង ដូចជាត្បាល់កិនទាញទឹងដៃ - បំពង់ស្នប់ - រទេះ ។ល។ ការចំរើនខាងមធ្យោបាយបង្កើតផល បណ្តាលឲ្យមានការប្រែប្រួលផ្លាស់ប្តូរជាច្រើនខាងផ្នែកសង្គម ជាពិសេស មុខងាររបស់ទាសកម្មករ ក៏បានរីកធំទូលាយឡើងទៀត ។ ហេតុទាំងនេះ បណ្តាលឲ្យមានការវិវត្តន៍ក្នុងមជ្ឈដ្ឋានសេដ្ឋកិច្ច ពោលគឺការផលិតផលដោយផ្អែកទៅលើទាសវណ្ណៈ ។

## ច– កំណើត និង រូបភាពដំបូងនៃរដ្ឋ

ការចំរើនខាងសេដ្ឋកិច្ច បណ្តាលឲ្យកើតបានជារដ្ឋ ។ យើងបានឃើញហើយថា ក្នុងសង្គមជាន់ដើម គេគ្មានអង្គការពិសេសនៃរដ្ឋបាលឡើយ ពោលគឺគ្មានរដ្ឋនេះឯងតែម្តងៗ

ក្រោយមក ថ្វីបើមានចំណងទាក់ទងជាកាតគោពរវាងសមាជិកនៃកុលសម្ពន្ធ ឬបក្សសម្ពន្ធក៏ដោយ ការចំរើនខាងសេដ្ឋកិច្ចនាំឲ្យកើតមានក្នុងផ្ទៃក្នុងនៃបក្សសម្ពន្ធ និងកុលសម្ពន្ធនោះនូវការប្រមូលផ្តុំជាក្រុម ជាបក្ស តាមស្ថានភាពសេដ្ឋកិច្ច និងតាមស្ថានភាពនៃសង្គមរបស់គេ ៗ វណ្ណៈសឹក-វណ្ណៈសង្ឃ បានប្រមូលផ្តុំជាក្រុម ហើយអំណាចក៏ធ្លាក់ទៅលើវណ្ណៈទាំងនោះត ៗ មក ៗ កន្លែងខ្លះ ក្រុមសិប្បករជាអ្នកកាន់អំណាចត្រួតត្រា ដូចជានៅបូលីណេស៊ី ក្រុមពួកអ្នកសង់ទូក កប៉ាល់ជាធំ ៗ ក្នុងតំបន់ដទៃទៀត ក្រុមពួកជាងបាយអ ឬក្រុមអ្នកបេះ សក្តិមន្តកថា ឬក៏ក្រុមអ្នកធ្លាក់របនាជាអ្នកកាន់អំណាច ៗ

ម្យ៉ាងទៀត ការបែកការងារបន្ទាប់បន្សំទាំងឡាយ បណ្តាលឲ្យសភាពស្មុគស្មាញនៃសង្គមរឹងរឹតតែមានទ្រង់ទ្រាយល្អិតល្អន់ណាស់ទៅទៀត ៗ ជាមួយនឹងការបែកការងារទៅតាមសមាជិកសង្គម ហើយបើគេបន្ថែមឲ្យសមាជិកក្នុងបក្សសម្ពន្ធជាមួយគ្នារៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធតែគ្នាឯងទៀតនោះ ការបែកសង្គមមនុស្សជា វណ្ណៈ ផ្សេង ៗ ក៏កើតមានឡើងដូច្នេះដែរ ដូចជា ការបែកក្រុមមនុស្សក្នុងសង្គមជាវណ្ណៈផ្សេង ៗ គ្នា នៅប្រទេសឥណ្ឌាជាដើម ៗ

ដូច្នេះក្នុងការវិវត្តន៍របស់ខ្លួន សង្គមជាន់ដើមមាននិន្នាការបែកជាពួក ជាក្រុម ជាវណ្ណៈស្របទៅតាមស្ថានភាពសេដ្ឋកិច្ចរបស់គេ ៗ ក្រុមណា ដែលមានគេគោរពច្រើននោះ ត្រូវបានទទួលកាន់អំណាចពិសេសទាំងឡាយដែលជាអគ្គការនៃរដ្ឋ ៗ យើងនឹងបរិយាយពីរដ្ឋនិងការលូតលាស់នៃរដ្ឋនៅពេលក្រោយ ៗ

## ឆ– សេចក្តីសន្និដ្ឋាន

ការសិក្សាវែកញែកដោយត្រួសៗ នូវសង្គមជំនាន់ដើម បានបង្ហាញឲ្យយើងឃើញថា គ្រប់កាលៈទេសៈ លក្ខណៈនៃការបង្កើតផល ជាបុព្វហេតុនៃការប្រែប្រួល និងការផ្លាស់ប្តូរ

នៃសណ្ឋានសង្គម ៗ ឯជំនឿ និងទំនៀមទំលាប់ វាគ្រាន់តែជាស្រមោលនៃលក្ខណៈសេដ្ឋកិច្ចរបស់សង្គមប៉ុណ្ណោះ ៗ

តែចូរកុំយល់ដោយងាយ ៗ ពេកថា តែកាលណាលក្ខណៈសេដ្ឋកិច្ចផ្លាស់ប្ដូរ ជំនឿ និងទំនៀមទំលាប់ប្រែប្រួលជាមួយគ្នាដែរនោះ ៗ ផ្ទុយមកវិញ ក្រោយពីការប្រែប្រួល នៃលក្ខណៈសេដ្ឋកិច្ច មនុស្សយើងនៅតែរក្សាទុកអស់រយៈកាលដ៏យូរ នូវទំនៀមទំលាប់ចាស់ នូវជំនឿចាស់ដដែល ៗ តែក្នុងករណីណាក៏ដោយ ទស្សនៈខាងលទ្ធិ ទស្សនៈខាងនយោបាយ វាតែងតែចេញមកពីរបៀបបង្កើតផល ចេញមកពីលក្ខណៈសេដ្ឋកិច្ចរបស់សង្គម ទោះបីការវិវត្តន៍នៃទស្សនៈខាងលើនេះ មានសភាពជាស្វ័យប្រវត្តិក៏ដោយ ៗ

ជាអវសាន សូមជំរាបថា ស្ថានភាពរបស់មនុស្សក្នុងសង្គមជាន់ដើម មានសភាពមិនទៀងទាត់ឡើយ ដោយឧបករណ៍បង្កើតផល និងគ្រឿងសាស្ត្រាវុធសម្រាប់ការពារខ្លួន មានលក្ខណៈអន់ថយ មិនពូកែសក្តិសិទ្ធិ ៗ ការខ្លាចសេចក្ដីល្ងង់ខ្លៅ ហើយនិងជំនឿមិនសមហេតុផលទាំងឡាយ បានគ្របដណ្ដប់ទៅលើគ្រប់សកម្មភាពរបស់គេ ៗ ស្ថានភាពនេះបានបន្តមកដល់សង្គមមនុស្សក្នុងសតវត្សទី ២០ នេះទៀតផង ៗ

ផ្ទុយពីនេះវិញ ក្នុងសង្គមជាន់ដើម គេសង្កេតឃើញនូវគុណសម្បត្តិខ្លះ ដែលច្រើនតែបាត់បង់អស់ក្នុងសង្គមយើងទំនើប ដោយសេចក្ដីនិន្នាឈានិស ដោយការបែកគ្នាជាក្រុមជាវណ្ណៈជាពណ៌និនយោបាយ ៗ គុណធម៌ទាំងនោះ គឺស្វាមីភក្តិរបស់បុគ្គលម្នាក់ ចំពោះផលប្រយោជន៍រួមរបស់បក្សសម្ពន្ធ គឺសេចក្ដីស្មោះត្រង់ និងសេចក្ដីទុកចិត្ត ចំពោះសមាជិកក្នុងបក្សសម្ពន្ធជាមួយគ្នា ៗ តែយ៉ាងណាក៏ដោយ គេក៏មិនអាចទុកសង្គមបុរាណ ដូចជាស្ថានសួគ៌មួយក្នុងលោកនេះ ឬ សួគ៌មួយគួរឲ្យស្ដាយសោះឡើយ ៗ

★ ★ ★

# វេយ្យាករណ៍អំពី "រ"

អ៊ួង សុខង
វិទ្យាល័យឥន្ទ្រទេវី

ពាក្យដែលមាន "រ" នឹងគ្មាន "រ" នៅពីមុខ ជាបញ្ហាមួយយ៉ាងធំ ដែលកើតឡើងចំពោះអ្នកសិក្សាអក្សរសាស្ត្រខ្មែរ ក្នុងការសរសេរឲ្យត្រឹមត្រូវ តាមអក្ខរាវិរុទ្ធ ។

សិស្សានុសិស្សទាំងឡាយតែងតែត្អូញត្អែជារឿយ ៗ ចំពោះមុខសាស្ត្រាចារ្យថា : ខ្មែរយើង ពិបាកតែរឿង រ មិន រ នេះជាងគេ ។ ការពោលដូចនេះ ពិតជាសមហេតុសមផលដែរ ។ តែការពិបាកនេះ ក៏មិនមែនជាបញ្ហាដោះស្រាយមិនរួច រកមិនចេញ ក៏ទេដែរ ។ ការសិក្សាស្រាវជ្រាវ នឹងការពិសោធន៍សាកល្បងខ្លះៗ ដែលយើងបានធ្វើរួចមកហើយ បញ្ជាក់ប្រាប់យើងថា គេអាចដោះស្រាយរួច ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកយកសេចក្ដីសង្កេតខ្លះ ចំពោះបញ្ហា "រ" មិន "រ" ដូចជាការសាកល្បង ដូចតទៅនេះ ៖

## ១- វិធីបំណាំពាក្យខ្លះ ដែលគ្មាន "រ" នៅពីមុខ

ក- ពាក្យ ឬ ព្យាង្គបើកទាំងឡាយណា ដែលកើតឡើងពីព្យញ្ជនៈផ្ញើជើង "្រ" គេមិនដែលដាក់ "រ" ពីមុខទៀតទេ ។

ឧទាហរណ៍ : ក្រ = ទ័លក្រ ក្រា = ក្រាកាប់សណ្ដែក

គ្រ = ក្រសាំង គ្រ គ្រា = គ្រានេះ គ្រានោះ -ល-

១- ពាក្យទាំងឡាយណា ដែលមានព្យាង្គ "ក្រ" នៅខាងដើម គេមិនដែលដាក់ "រ" ថែមទៀតទេ ។

ឧទាហរណ៍ : ក្រទីក្រទា ក្រសែក្រក ក្រយាស្វាយ

ក្រឡេក្រឡា ក្រឡ ក្រពើ ... – ល –

លើកលែង តែពាក្យ ប៉ុន្មានខាងក្រោមនេះចេញ :

– ក្រមរ ( ក្រមរគម ក្រមរឈើ )

បានជាពាក្យ "ក្រមរ" នេះ មាន "រ" ព្រោះខ្លាចច្រឡំនឹងខ្យល់ "ក្រម" = ក្រុំ

កុងពាក្យ ចៅក្រម ឬ ច្បាប់ក្រម ។

– ក្រញូវ ( ក្រញូវដៃ ត្បូងមួយក្រញូវ )

ពាក្យក្រញូវបានជាដាក់ "រ" ថែម ដើម្បីកុំឱ្យច្រឡំយក "ញូ" ជាតួប្រកប ។

– ក្រសារ ( កុកក្រសារ )

បានជាដាក់ "រ" ពីមុខពាក្យក្រសារនេះ ដើម្បីឱ្យសមតាមន័យដែលបញ្ជាក់ថា

សត្វកុកជាសត្វក្រសារ : ( គ្មានសារៈ ) ព្រោះគេបង្រៀនក្រចេះនិយាយ ខុសពីសត្វសេក

នឹង សារិកាកែវ ( កុងរឿង អឹមជាងអៀម សៀមជាងស្រដី ) ។

គ– ពាក្យទាំងឡាយដែលមានព្យាង្គ "រ" នៅខាងដើមគេមិនដាក់ "រ" ថែម

ទៀតទេ ។

ឧទាហរណ៍ : រកា ( ដើមរកា ) រងា ( ខែរងា ) រញ៉ៃ ( ក្មេងមាត់រញ៉ៃ - រញ៉ៃរញ៉ូវ )

រយ៉ា ( ក្មេងពាក់រយ៉ា ) រលា ( ផ្កុយពីរម្យូរ ) រវើ ( រវើរវាយ ) – ល – ។

លើកលែង តែពាក្យ ៤ ម៉ាត់ ខាងក្រោមនេះចេញ :

របរ ( របររកស៊ី ) រលរ ( សើមមាត់រលរ )

រម្យូរ ( ក្រដាស់នេះរម្យូរ ) ររហៀរ ( ក្រររហៀរ ) របារ ( របាររបង )

កំណត់បំណាំ ៖

– ពាក្យ "របរ" នឹង "រលរ" បានជាមាន "រ" ថែមពីមុខទៀត ព្រោះខ្លាច ប្រឡំនឹងខ្យល់ "របេ" កន្ត្រាក្យ "រៀបរប" នឹង "រល" កន្ត្រាក្យ "សើរល" ។

– "រម្សូរ" ជាពាក្យផ្ទុយនឹង "រលោ" ដោយវលាគ្មាន "រ" នៅពីមុខ - ដូច្នេះ រម្សូរ ត្រូវថែម "រ" មកទៀត ដើម្បីឲ្យខុសពីរលោ ។ បានសេចក្ដីថាឲ្យផ្ទុយគ្នា ទាំងរូប ទាំងន័យ ( រម្សូរ - រលោ ) ។

– "រហៀរ" ( គ្ររហៀរ )

សូមនឹកពាក្យកាសិតមួយឃ្លា ពោលថា ៖ "គ្រហៀរគ្រប" ។

ហេតុដូច្នេះហើយបានជា រហៀរ ថែម "រ" មួយមកទៀត ដើម្បីឲ្យបាន ហៀរគ្របដូចបាយ ព្រោះតែការថែមអង្ករមួយកំប៉ុងលើស ។

– របារ ( របាររបង )

គេដាក់ "រ" នៅពីមុខ ដើម្បីឲ្យឆាយចំណាំន័យនៃពាក្យនេះ ព្រោះអាច ប្រឡំនឹងពាក្យ "របា" ដែលប្រែថា ពូជពង្ស ខ្សែស្រឡាយ ពង្សាវតារ ឬ ការនិយាយ រៀបរាប់ ( របាក្សត្រខ្មែរ - ស្ដាប់របា ) ។

ឃ– ពាក្យទាំងឡាយណា ដែលកើតឡើងពីព្យញ្ជនៈ "រ" នឹង "ឡ" គេមិន ដាក់ "រ" ថែមពីមុខទៀតដែរ ។

ឧទាហរណ៍ ៖ រេក ( ដើររេក ) រើ ( រើរុះ ) រូ ( រអិលរូ )

ឡូឡា = មាត់ឡូឡា ឡ ៗ = យំឡ ៗ ឡៃ ៗ ... – ល – ។

ពាក្យច្រើនព្យាង្គ ៖ ឧក ( ចិត្ត ទ្រូង ) ឈើក ( ប្រដាប់គម្បាញ ) ក្រឡ ( ផ្អមក្រឡ ) ក្រឡា ... – ល – ។

ង– ពាក្យពីរព្យាង្គ ដែលកើតមកពីព្យញ្ជនៈដាមួយគ្នា គេតែងដាក់ "រ" នៅពីមុខព្យាង្គទីពីរជានិច្ច បើព្យាង្គនោះជាព្យាង្គបើក លើកលែងតែពាក្យ "បរបា" មួយចេញ ។

ឧទាហរណ៍ : សសរ បបរ កករ កក្ករ សសៀរ ទទូរ... –ល–

ចំពោះព្យាង្គទី ១ គេមិនដាក់ "រ" ពីមុខទេ បើព្យាង្គទី១នោះជាបុព្វបទ ( préfixe )

ឧទាហរណ៍ : កកិល ញញក់ បញ្ចោប

កកិត ញញើត ពពាត់

គគុក ផផុស ពពូន

គគ្រាក់ តតុប មមុល

បបេស ទទាក់ មមើក

ជជុះ ទទូប សសិត

ជជ្រក បប៉ុប សសុស... –ល– ។

រីឯពាក្យ សរសៃ ជរជាយ គរគោក ជរជួរ

បរបា សរសើរ សរសេរ ដេរដាស

ឃោរឃៅ នរនាថ... ទាំងនេះ បានជាមាន "រ" នៅពីមុខ

ព្យាង្គទី ១ ព្រោះព្យាង្គទី ១ នេះមិនមែនជាបុព្វបទ ។

## ២– វិធីចំណាំអក្ខរាវិរុទ្ធរបស់ពាក្យ តាមការប្រៀបធៀបអត្ថរូបនឹងអត្ថន័យ

– កំជរ : គួរចំណាំថា : តើអ្នកណា ជាអ្នកឈរកំដរគេ ?

គឺ "រ" ដែលឈរពីមុខនេះឯង ។

– កំព្រា : បានជាគ្នាកំព្រាទៅតែឯកឯង ព្រោះគ្មាននរណាមកជួយកំដរ ជួយការពារ ។

– ការពារ : គឺ " រ " ដែលឈរពីមុខនេះ ហើយជាអ្នករក្សាការពារ ។

– មីរដេរដាស : ព្រោះតែមាន " រ " ទៅឈរឡូកឡំជាមួយផង ទើបមើលទៅឃើញច្រើនមីរដេរដាសដូច្នេះ ។

– ទូ : តាមធម្មតា ទូគេតែងតែពាក់សោជានិច្ច - ហេតុដូច្នេះហើយ បានជា " រ " មិនបាច់ទៅឈរ ចាំយាមទូនោះទៀត ។

– ចំហ : បានជាចំហដ្បូយ៉ាងនេះ ព្រោះ " រ " មិនមកខ្ទប់ពីមុខ មិនមកបិទ ។ បើប្រសិនមាន " រ " វិញ នោះវាមិនចំហទេ គឺវាទៅជាជិតទៅហើយ ។

– ដួរ : បានជាមានដួរត្រង់ល្អយ៉ាងនេះ ព្រោះមាន " រ " ជាអ្នកឈរតម្រង់ពីមុខ ។

– ទារ : គេតែងពោលថា ទាររក ( = រក៍ )

– ទេរ - ទោរ : ដោយឃើញទេរ ឬ ទោរដូច្នេះហើយ ទើបគេយក " រ " ទៅទល់ដើម្បីកុំឲ្យដួល ។

– ប្រវេប្រវា : ព្រោះតែគ្នានៅតែម្នាក់ឯង គ្មាន រ ទៅជួយ ទើបប្រវេប្រវាយ៉ាងនេះ ។

– ដោយសារ នឹងដោះសា : ដោះសាបានរួចខ្លួនពី រ តែមកជាប់ នឹងដោយសារនេះវិញ បានសេចក្ដីថា : ខាងនោះដោះសារួចខ្លួន តែមកជាប់ឯដោយសារខាងនេះទៅវិញ ។

– មាយា នឹងមារយាទ : មនុស្សមាយាទុកអ្វីក៏មិនគង់ដែរ គឺឲ្យបាត់អស់ ។ ចំពោះគេអ្នកមានមារយាទវិញ គេតែងទុកដាក់បានគង់វង់ជានិច្ច - ហេតុដូចនេះហើយបានជាគេឃើញ មាយា ធ្លាក់ " រ " បាត់ពីខ្លួន រីឯមារយាទវិញ រ ស្ថិតនៅដដែល ។

– វារ : ក្មេងដែលទើបតែចេះវារ គេត្រូវតែយករបារឈើទៅបាំង ឬ ឲ្យមនុស្សម្នាក់នៅឈរថែរក្សាជានិច្ច ។ បើមិនដូច្នេះទេ ក្មេងនោះនឹងវារធ្លាក់

ជាមិនខាន ។ ហេតុនេះហើយ ទើបវាមាន "រ" នៅពីមុខដែលទុកដូចជារបាំរសំពប់បាំង ។

— ស្ទើ - ស្ទើរ: ព្រោះស្ទើរទើបគេថែម "រ" - បើស្ទើទៅហើយចាំបាច់ថែម "រ" ធ្វើអ្វីទៀត ។

— ហូរហៀរ: ហេតុអ្វីបានជាហូរហៀរចេញមកក្រៅ ?

ព្រោះ "រ" ចូលទៅបន្ថែម ទើបហូរហៀរចេញមកក្រៅយ៉ាងនេះ ។

បើគ្មាន "រ" វាមិនកំពប់ហូរហៀរដូច្នេះទេ គឺគ្រាន់តែពេញល្មម ។

— ដូរ - ទូរ: ដើម្បីដូរគ្នា ឬ ទូរគ្នាកើតលុះត្រាតែមានពីរ - ហេតុដូច្នេះហើយ បានជាគេថែម "រ" មកទៀត ដើម្បីឲ្យបាន ពីរ —ល— ។

ចំពោះពាក្យឯទៀតៗ ដូចជា: សង្ហា ហ៊ឹហា ស្ទើ ឬ ស្ទើរ ឈរ ដើរ ហ៊ោ ក្បែរ គរ គ ស សរ —ល— ក៏មានចំណាំដូច្នោះដែរ ។

ការលើកយកវិធីរបៀបនេះ មកអធិប្បាយក្នុងការចំណាំពាក្យ គ្មានបានផ្អែកទៅលើគោលមូលភាពអ្វីជាដុំកំភួនក៏ពិតមែនហើយ តែក៏មិនមែនជាឥតប្រយោជន៍សោះដែរ ។ ដោយហោចណាស់ ក៏យើងអាចចាត់ទុកបានថា ជាគំនិតមួយថ្មី ឬ ជាវិធីក្លីភ្លើមួយ ដើម្បីចំណាំពាក្យកុំឲ្យភ្លេចបានដែរ ។

## ៣– សេចក្តីសង្កេតចំពោះមុខងារនៃព្យញ្ជនៈ “ រ ”

តួ "រ" បើនៅខាងចុងព្យាង្គរបស់ពាក្យ មានមុខងារដូចតទៅ :

ក– ដើម្បីសម្រួលក្នុងការអាន កុំឲ្យច្រឡំ ព្យញ្ជនៈខ្យល់ច្រកប នឹងព្យញ្ជនៈដែលជាព្យាង្គរបស់ពាក្យ ។

ឧទាហរណ៍: គគរ ( កុំឲ្យច្រឡំនឹងពាក្យ ទឹកគក )

ក្រមរ ( " ច្បាប់ក្រម, ចៅក្រម )

បបរ ( " របៀបរបប )

របរ ( " រៀបរប )

រលរ ( " ស្វើរល )

១- ជាខ្យល់ប្រកប ជំនួស តួ " ល "

រណារ គេអាចអានថា រណាល់ ខ្ទរ គេអាចអានថា ខ្ទល

អារ " អាល់ កណ្ដុរ " កណ្ដុល

ការ " កាល់ សម្បុរ " សម្បុល

ចារ " ចាល់ ហឹរ " ហឹល

ក្បារ " ក្បាល់ ញ័រ " ញាល់

តែបើ " រ " នេះនៅខាងដើមពាក្យវិញ មានមុខងារផ្សេងទៅទៀតគឺ :

ក- ដើម្បីបញ្ជាក់ន័យ នឹងសភាពនៃការផ្ទួនពាក្យច្រើនដង សាចុះសាឡើង ឬ ជំនួសលេខទោ « ៗ » បើ " រ " នោះពជាបុព្វបទ ។

ឧទាហរណ៍ : ររើក ឬ រើកៗ ច្រើនដង - រញ៉ែ ឬ ញ៉ែៗ ច្រើនដង - ររៀម គឺច្រើនពាសពេញ រពឹស គឺធ្វើនេះហើយ ធ្វើនោះទៀតមិនឈប់ឈរ - រដឹក គឺតៗ គ្នារកេតរកូត បន្តៗ គ្នាជាប់ជានិច្ច . . . -ល- ។

១ - ដើម្បីជំនួសព្យញ្ជនៈ " ល " ផ្ញើដើម

ឧទាហរណ៍ : រវិច ជំនួស ល្វិច រគង ជំនួស ល្គង

រហែង " ល្ហែង រលា " លលាដ៍

រហាហៅ " ល្ហល្ហៅ រអាង " ល្អាង -ល- ។

តាមមុខងារខាងលើនេះ យើងអាចសន្និដ្ឋានបានថា : តួ " រ " អាចជំនួសតួ " ល " បាន ជាច្រើនអន្លើ គឺថាបើនៅខាងចុង " រ " នោះជាខ្យល់ប្រកប ហើយនៅខាង ដើម " រ " នោះ មានខ្យល់ជា " ល " ផ្ញើដើមវិញ ។



ដើម្បីរឹតចំណងមិត្តភាព សាមគ្គីភាពរវាងបុគ្គលិកសិក្សា មិត្តយើងនៅសាលានានា បានទាំគ្នាប្រកួតកីឡាផ្សេងៗ ជាបន្តបន្ទាប់គ្នាដូចតទៅ :

## ★ អនុវិទ្យាល័យព្រះបិតាឯកភាព

១៨ ធ្នូ ១៩៦៦ — គឺជាការប្រកួតកីឡារវាងអនុវិទ្យាល័យព្រះបិតាឯកភាព ដឹកនាំដោយមិត្ត ស៊ិន អួន និងវិទ្យាល័យសន្តិភាព ដឹកនាំដោយមិត្ត ចន្ទ ទិត ។ ជ័យជំនះបានទៅខាងអនុវិទ្យាល័យព្រះបិតាឯកភាព ។ តែចាញ់ ឬ ឈ្នះ មិនសំខាន់-ការសំខាន់គឺនៅត្រង់ការរួបរួមគ្នា កងការនាំគ្នាទៅដួតទឹកនៅស្រះស្រង់ ការដប់លៀងនៅដើងភ្នំគាមោក ការប្រគំភ្លេងពីរោះៗ និងការដើរមើលបូជនីយដ្ឋានវត្តគាមោកឯនោះទៅវិញ ។ ហេតុនេះហើយបានជា គេកត់សំគាល់ឃើញសេចក្តីអាឡោះអាល័យមួយយ៉ាងធំ បានកើតមានចំពោះមិត្តយើងពល់រូប នៅពេលបែកគ្នា នាម៉ោង ៣ រសៀល ។

## ★ អនុវិទ្យាល័យព្រែកសណ្ដែក

២៤ ធ្នូ ១៩៦៦ – ប្រកួតកីឡារវាងអនុវិទ្យាល័យព្រែកសណ្ដែក និងអនុវិទ្យាល័យដីហែ ( កំពង់ចាម ) ។ ឯលទ្ធផលគឺ :

១– កីឡាបាល់ទះ : មិត្តព្រែកសណ្ដែកឈ្នះ ៣ ទល់ នឹងសូន្យ ។

២– កីឡាបាល់បោះ : មិត្តដីហែឈ្នះ ២៩ ទល់ នឹង ២៥ ។

៣– កីឡាកូនឃ្លីលើតុ : ក្នុងការប្រកួត ៥ ដង មិត្តព្រែកសណ្ដែកមានជ័យ ៤ ដង - មិត្តដីហែ មានជ័យ ១ ដង ។

## ★ អនុវិទ្យាល័យទេពប្រណម្យ

២២ មករា ១៩៦៧ – មិត្តនៅអនុវិទ្យាល័យទេពប្រណម្យ បានទៅប្រកួតកីឡាផ្សេងៗ នៅឯអនុវិទ្យាល័យជើងឆ្នុក ។

៥ កុម្ភៈ ១៩៦៧ – មិត្តយើងបាននាំគ្នាទៅប្រកួតជាមួយមិត្តនៃវិទ្យាល័យព្រះសុរាម្រឹត ឯកំពង់ឆ្នាំង ។

១៨ កុម្ភៈ ១៩៦៧ – មិត្តយើងបានទទួលមិត្តនិស្សិតសាស្ត្រាចារ្យ ដែលទៅពីភ្នំពេញ ដើម្បីប្រកួតកីឡានៅក្នុងអនុវិទ្យាល័យរបស់ខ្លួន ។

គិតទៅ មិត្តយើងនៅអនុវិទ្យាល័យទេពប្រណម្យ ដែលមានមិត្ត លី គឹមអ៊ីជាចាងហ្វាង សុទ្ធតែជាអ្នកនិយមកីឡាមិត្តភាព និយមការគំសាន្តមួយថ្លៃថ្នូរ និងស្អាតស្អំ ។

## ★ អនុវិទ្យាល័យស្ដី ( កំពង់ចាម )

៤-៥ កុម្ភៈ ១៩៦៧ – មានការប្រកួតកីឡាមិត្តភាព រវាងមិត្តនៅអនុវិទ្យាល័យស្ដី

និងអនុវិទ្យាល័យពាមជីកង ។ មុននេះ មិត្តយើងធ្វើការប្រកួតយូរ – ប្រកួតចំនួន ២ ថ្ងៃ ។ ឯលទ្ធផលមានដូចតទៅ :

១– កីឡាបាល់ទាត់ : មិត្តខាងស្ពឺ ឈ្នះ ៣ ទល់នឹង ២ ។

២– កីឡាបាល់ទះ : មិត្តពាមជីកង ឈ្នះ ៣ ទល់នឹង ២ ។

៣– កីឡាបាល់បោះ : មិត្តពាមជីកង ឈ្នះ ២២ ទល់នឹង ១៥ ។

២៩ មករា ១៩៦៧ – ជាលើកទី ២ មិត្តនៅអនុវិទ្យាល័យស្ពឺ បានប្រកួតកីឡាជាមួយមិត្តដែលមកពីអនុវិទ្យាល័យកំពង់ថ្ម ( កំពង់ធំ ) ។ ដោយមិត្តនៅស្ពឺ ជាអ្នកចូលចិត្តកីឡា បានជាមិត្តប្រមូលយកជ័យជំនះបានច្រើន ពីព្រោះ :

១– កីឡាបាល់ទះ : មិត្តខាងស្ពឺ ឈ្នះ ៣ ទល់នឹង ១ ។

២– កីឡាបាល់ទាត់ : – ៧ – ១ ។

តែទោះជាយ៉ាងណាក៏ដោយ ឈ្នះក៏ដោយ ចាញ់ក៏ដោយ ក៏បរិយាកាសមិត្តភាព សាមគ្គីភាព នៅតែមានជានិច្ចរវាងមិត្តយើង ក្នុងអនុវិទ្យាល័យស្ពឺក្តី ទេពប្រណម្យក្តី ព្រះបិតាឯករាជ្យក្តី ព្រែកសណ្តែកក្តី ពីព្រោះការប្រកួតកីឡាយើងជាការរឹតបំណងមិត្តភាព ដែលផ្ទុយគ្នាស្រឡះពីសម័យអាណានិគម-សម័យកីឡាស្លាប់ដៃ កីឡាព្យួរដៃ ដ៏គួរខ្ពើម !

ជយោ កីឡាមិត្តភាព !

★

# ជីវភាពមិត្តយើង

ក្រៅអំពីការរឹតចំណងមិត្តភាព សាមគ្គីភាពតាមមធ្យោបាយកីឡា មិត្តយើងទាំងឡាយនៅបានប្រើមធ្យោបាយផ្សេង ៗ ដូចតទៅ :

★ អនុវិទ្យាល័យទេពប្រណម្យ

កាលពីខែធ្នូ ១៩៦៦ មិត្តយើងជាច្រើន មានមិត្ត លី គឹមអ៊ី ជាដើម បាននាំគ្នាទៅប្រសិទ្ធិពរ សរសើរមិត្ត ពុធ ដួប និងភរិយា ដែលទើបនឹងបានកូនប្រុសមួយយ៉ាងស្រស់ ។ មួយខែក្រោយមក មិត្ត លី គឹមអ៊ី ត្រូវទទួលគេវិញ ពីព្រោះមុននេះ ភរិយារបស់មិត្តបានសំរាលកូនស្រីមួយដ៏ប្រិមប្រិយ៍ ។

មួយខែក្រោយមកទៀត គេនាំគ្នាទៅចោមរោមសរសើរមិត្ត ហួត ហី ម្ដង ពីព្រោះមិត្តយើងខាងក្រោយនេះ ទើបនឹងបានកូនប្រុសមួយ គ្រាន់នឹងបីបមថ្នមប្រលែងលេងដូចគេឯងដែរ ។

★ វិទ្យាល័យគន្ធបុប្ផា

កាលពីខែធ្នូ កន្លងទៅនេះ មិត្ត យឹម សន្ធរ នាយកវិទ្យាល័យទើបនឹងបានកូនស្រីមួយ ។ ដើម្បីរួមរីករាយជាមួយ មិត្តតំណាងយើងនិងមិត្តឯទៀតៗ ដូចជា មិត្ត មួន មិត្ត ប៉េង ឈា ជាដើម បាននាំគ្នាទៅសាកសួរសុខទុក្ខ និងប្រសិទ្ធិពរមាតាបិតា និងទារកថ្មីនេះ ។

ប៉ុន្តែ មិត្ត តាំ ធុនហួត ជាឪពុកអភ័ព្វណាស់ ពីព្រោះកូនដំបូងរបស់មិត្ត កើតហើយក៏ស្លាប់ទៅវិញ ។ មិត្តតំណាងយើងក៏បានទៅជួយរំលែកទុក្ខនេះ ពីមិត្តយើងដែរ ។

## ★ អនុវិទ្យាល័យកំពង់ត្របែក

កាលពីថ្ងៃ១២ មករា ១៩៦៧ មិត្តយើងនៅកំពង់ត្របែក បានចាត់តំណាងម្នាក់ទៅសួរសុខទុក្ខ នឹងនាំវិភាគទានចំនួន ៦២៥ រៀល ទៅជូនមិត្ត ខៀវ យ៉េន ដែលនៅព្យាបាលជំងឺខ្នែងពោះវៀន ឯមន្ទីរពេទ្យមិត្តភាពខ្មែរ - សូវៀត ។ មិត្តយើងក៏បានផ្ញើតបទៅវិញ នូវអំណរគុណ នឹងសេចក្តីនឹករលឹករបស់ខ្លួន ។

ចំណែក ឯមិត្ត ទុំ ប៊ុនផែល ក៏មានទុក្ខធ្ងន់ណាស់ ដោយឪពុករបស់មិត្ត បានទទួលអនិច្ចកម្ម ។ ក្នុងមរណទុក្ខនេះ មិត្តយើងនៅកំពង់ត្របែកបាននាំគ្នាចូលរួមរំលែកគ្រប់ៗគ្នា ហើយបានរៃបច្ច័យចូលបុណ្យសពនេះផង ។ ឆ្លៀតឱកាសនេះ យើងទាំងអស់គ្នា ជាសមាជិកគ.នាយក ក៏សូមចូលរួមរំលែកមរណទុក្ខរបស់ មិត្ត ប៊ុនផែល ផងដែរ ។

## ★ អនុវិទ្យាល័យព្រៃដើមថ្នឹង

យើងបានដំណឹងតាម មិត្ត ប៉ុប សេង ពាំងហ្វាងអនុវិទ្យាល័យមកថា មិត្តយើងនៅអនុវិទ្យាល័យខាងលើនេះ បានរៃបច្ច័យគ្នាចំនួន ៣ លើក - មួយបាន ៩៥០ រៀល ដើម្បីចូលបុណ្យសពបងរបស់មិត្ត ស៊ឹម ស្រួ - មួយបាន៩១០ រៀល ដើម្បីចូលបុណ្យសពមាតា មិត្ត មាន ហុង - មួយទៀត បាន៨០០ រៀល ដើម្បីចូលបុណ្យសពជីដូន មិត្ត ឡុច សោរឹម ។ ចំពោះសេចក្តីឈឺផ្សាលខាងលើនេះ មិត្តអភ័ព្វទាំង ៣ នាក់ខាងលើ បានផ្ញើនូវសេចក្តីថ្លែងអំណរគុណមួយ ចំពោះ

មិត្តចាងហ្វាង និងមិត្តរបស់ខ្លួនឯងទៀតៗ ដែលខ្លួនសូមប្រសិទ្ធិពរឲ្យបានជួបតែនឹងសេចក្ដីសុខចំរើនគ្រប់ប្រការ ។

យើងខ្ញុំទាំងអស់គ្នា ជាសមាជិកគ.នាយក ស.ស.១ ក៏សូមមិត្តទាំង ៣ ខាងលើ អនុញ្ញាតឲ្យយើងចូលរួមរំលែកមរណទុក្ខដ៏ធំនេះ ជាមួយមិត្តផង ។

## ★ អនុវិទ្យាល័យព្រែកឯង

តាមការដឹកនាំរបស់ មិត្ត ប៉ី សូឃិន ចាងហ្វាងអនុវិទ្យាល័យ សាស្ត្រាចារ្យនិងសិស្សានុសិស្សទាំងឡាយ បានរៃបច្ច័យចំនួន៧៩០រៀល ដើម្បីយកទៅរំលែកទុក្ខគ្រួសារ ពូ រ៉ៃន មីង នួន ជាងកាត់សក់ ដែលត្រូវភ្លើងឆេះផ្ទះអស់ កាលពីថ្ងៃ ១៥ មករា ១៩៦៧ នេះ ។

យើងសូមសរសើរមិត្ត ប៉ី សូឃិន មិត្តសាស្ត្រាចារ្យ និងសិស្សានុសិស្ស ទាំងអស់ខាងលើនេះ ដែលបានពង្រីកសាមគ្គីភាពពុំមែនតែក្នុងគ្រប់ខណ្ឌអនុវិទ្យាល័យខ្លួនប៉ុណ្ណេះទេ តែបានធ្វើឲ្យរីកដល់ប្រជារាស្ត្រខ្សត់ខ្សោយនានាថែមទៀតផង ។

★

ម្យ៉ាងទៀត យើងសូមសរសើរមិត្ត អាំង យូអាំង ដែលទើបនឹងបានកូនប្រុសមួយ - សូមមិត្តនិងភរិយាព្រមទាំងបុត្រ មានសេចក្ដីសុខត្រជាក់ត្រជុំ ក្នុងគ្រួសារតរៀងទៅ ។

ទីបំផុត សូមប្រសិទ្ធិពរជ័យវរជូនមិត្ត ឱម ភ៉ន់ដន ដែលទើបនឹងរៀបមង្គលការជាមួយនាង ប៉ាវ ស៊ីយ៉ាដេត ។ សូមគ្រួសារថ្មីនេះសុខសប្បាយ ជួបតែនឹងសុភមង្គលវិបុលសុខ កុំបីឃ្លៀងឃ្លាតឡើយ ។

# ហិបប្រាក់សមាគម

យើង *បានទទួលវិភាគទានពីសាលានានាតមកទៀតដូចតទៅ :*

| | | | |
|---|---|---|---|
| មហាវិទ្យាល័យ | សិល្បៈ នឹងមុខរបរ ( ភ្នំពេញ ) | 1160 | រៀល |
| — | គរុកោសល្យ - អក្សរសាស្ត្រ - វិទ្យាសាស្ត្រ | 320 | — |
| មណ្ឌលហ្វឹកហ្វឺន គរុកោសល្យ កំពង់កន្ទួត | | 1140 | — |
| វិទ្យាល័យ | ព្រះឧទ័យ ( តាកែវ ) | 1740 + 1560 | — |
| — | ព្រះសីហនុ ( កំពង់ចាម ) | 15.000 | — |
| — | ព្រះកុសុមៈ ( ក្របេះ ) | 500 + 360 | — |
| — | ជ័យវរ្ម័នទី ៧ ( ជីតជ្ល ) | 540 | — |
| — | ព្រះយុគន្ធរ ( ភ្នំពេញ ) | 720 | — |
| — | ព្រះស៊ីសុវត្ថិ ( ភ្នំពេញ ) | 1800 | — |
| — | ព្រះគន្ធបុប្ផា ( ព្រៃទទឹង - កំពង់ចាម ) | 500 + 520 | — |
| — | ព្រះសុរិយោវង្ស ( ស្វាយរៀង ) សំណល់ពីឆ្នាំ ១៩៦៦ | 2280 + 2365 | — |
| — | ឥន្ទ្រទេវី ( ភ្នំពេញ ) | 840 | — |
| — | សុរិយាវរ្ម័នទី ២ ( សៀមរាប ) | 1000 + 1200 | — |
| — | ព្រះកុសុមៈ ( ក្របេះ ) | 360 | — |
| — | សន្តិភាព ( កំពង់ស្ពឺ ) | 940 | — |
| — | សូរិយោវង្ស ( ស្វាយរៀង ) | 2220 | — |
| — | ព្រះអង្គឌួង ( ព្រៃវែង ) | 2002 | — |
| — | ព្រះបាទសុរាម្រឹត ( កំពង់ឆ្នាំង ) | 1667 | — |
| អនុវិទ្យាល័យ | រស្មីសម្តេចឪ ( ព្រែកឯង - កណ្តាល ) | 200 | — |
| — | សាលាលេខប្រាំ ( កំពង់ឆ្នាំង ) | 260 + 340 + 240 + 870 | — |
| — | កូនចៅសម្តេចឪ ( អង្គតាសោម ) | 1020 | — |

| | | | |
|---|---|---|---|
| អនុវិទ្យាល័យ | ព្រែកពោធិ៍ ( កំពង់ចាម ) | 760 | រៀល |
| — | មោង ( បាត់ដំបង ) | 900 | — |
| — | ពាមជីកង ( កំពង់ចាម ) | 1179 | — |
| — | ព្រែកកក់ ( ស្ទឹងត្រង់ - កំពង់ចាម ) | 186 + 37 + 226 | — |
| — | ឯកភ្នំ ( បាត់ដំបង ) | 840 | — |
| — | ព្រះសីហនុរាជ ( ព្រែកតាមាក់ - កណ្ដាល ) | 1020 | — |
| — | ចំបក់ ( តាកែវ ) | 480 | — |
| — | ព្រះនរោត្ដម ( ភ្នំពេញ ) | 820 | — |
| — | ទឹកឃ្លាំង ( កណ្ដាល ) | 840 | — |
| — | កំពង់ក្ដី ( សៀមរាប ) | 1000 | — |
| — | ព្រែកគយ ( កណ្ដាល ) | 2160 | — |
| — | ឈូក ( កំពត ) | 280 | — |
| — | សុរិយាវង្សទី ១ ( កំពែង - ព្រៃក្របាស - តាកែវ ) | 800 | — |
| — | ព្រែកសណ្ដែក ( ព្រៃវែង ) សំណល់ពី ៦៤ - ៦៦ | 500 | — |
| — | គិរីវង្ស ( តាកែវ ) | 600 | — |
| — | ទេពប្រណម្យ ( កណ្ដាល ) | 900 | — |
| — | អង្គប្រីយ៍ ( តាកែវ ) | 1120 | — |
| — | ជ័យវង្សទី ៣ ( ដីឥដ្ឋ - កណ្ដាល ) | 600 | — |

*ក្នុងនាមគណៈកម្មាធិការនាយក យើងសូមអរគុណជាពន់ពេក ចំពោះមិត្តជំនាន់ ស.ស.១ នៅសាលានានាខាងលើ ដែលបានចិត្តចំប្រមូលវិភាគទានផ្ញើទៅឲ្យសមាគម សំរាប់ចាត់ការសព្វសារពើ ។*

# យើងផ្ញើឲ្យគ្នា



... ពីសមាគមកម្ពុជបុត្រ ភ្នំពេញ

ក្រោយពីបានចុះអត្ថបទលោកនាយកមធ្យមសិក្សា ស្ដីពីបញ្ហាខេមរនីយកម្ម យើងបានទទួលសំបុត្រចំឡងមួយច្បាប់ ពីសមាគមកម្ពុជបុត្រ ដែលយើងសូមចុះផ្សំផ្សាយតទៅ :

ប្រធានគណៈកម្មាធិការនាយកសមាគមកម្ពុជបុត្រនៅភ្នំពេញ សូមជំរាប
សហជីវិននាយកមធ្យមសិក្សាក្រសួងអប់រំជាតិនៅភ្នំពេញ សូមជ្រាប ។

*សហជីវិន*

*នៅក្នុងទស្សនាវដ្ដីសមាគមសាស្ត្រាចារ្យខ្មែរ លេខ ២៣ ខែតុលា វិច្ឆិកា ធ្នូ ឆ្នាំទី ៨ មានអត្ថបទសហជីវិនមួយ និយាយរៀបរាប់អំពីខេមរនីយកម្មក្នុងការសិក្សានៅប្រទេសយើង ។ មតិសហជីវិនក្នុងអត្ថបទនេះ មានន័យច្បាស់លាស់ត្រឹមត្រូវតាមផលប្រយោជន៍ជាតិទាំងស្រុង ហើយសមហេតុផលស្របនឹងវិទ្យាសាស្ត្រ ព្រមទាំងគរុកោសល្យជាទីបំផុត ។*

*សហជីវិនបានលើកយកបញ្ហាធំនៃក្រសួងអប់រំជាតិ គឺការសិក្សាដែលប្រព្រឹត្តទៅតាមភាសាបារាំងមកហោង ហើយដោះស្រាយដោយប្រើវិធីជាតិ ពោលគឺ វិធីខេមរនីយកម្ម ។*

*សហជីវិនបានបញ្ជាក់យ៉ាងដាច់ណាត់ថា ការសិក្សាខ្មែរមិនអាចស្ថិតនៅដូចសព្វថ្ងៃនេះបានទេ ពីព្រោះសិស្សមិនពូកែភាសាបារាំង ជាហេតុនាំឲ្យសិស្សរៀនវិជ្ជាផ្សែងទៀត*

តាមភាសានោះមិនបានយល់ស្រួល ស្រូបយកចំណេះមិនគ្រប់គ្រាន់ ហើយមិនអាចមានសមត្ថភាពដែលត្រូវមានសំរាប់បំរើជាតិឡើយ ។

ប្រសិនបើចង់ដោះស្រាយបញ្ហានេះ សហជីវិនបានដៅយ៉ាងច្បាស់ថា ត្រូវតែធ្វើខេមរនីយកម្មក្នុងការសិក្សា ខេមរនីយកម្មដែលជាការមួយពិតជាធ្វើទៅកើត ហើយនាំមកលទ្ធផលប្រសើរថ្លៃថ្លា នឹងកិត្តិយសដល់ប្រទេសជាតិពិតប្រាកដ ។

អាស្រ័យទៅលើការពិសោធន៍ផ្ទាល់ខ្លួនជាច្រើនឆ្នាំមកហើយ នឹងទៅលើសភាពការសិក្សាទូទៅតាមរយៈភាសាបារាំងជាយាន សមាគមកម្ពុជបុត្រចាត់គោលគំនិត នឹងជំហរសហជីវិនក្នុងបញ្ហាខេមរនីយកម្មទុកជាត្រឹមត្រូវ មានខ្លឹមសារ មានថាមពលធំបំផុត ។

អាស្រ័យហេតុនេះ ហើយដោយយល់សេចក្តីស្នេហាជាតិពេញលេញទៅដោយសេចក្តីក្លាហានរបស់សហជីវិននេះ បានជាមហាសន្និបាតសមាគមកម្ពុជបុត្រ សូមសរសើរសហជីវិនយ៉ាងស្មោះស្ម័គ្រ ហើយសូមគាំទ្រយ៉ាងម៉ឺងម៉ាត់នូវគោលជំហររបស់សហជីវិនចំពោះការសិក្សាភាសាជាតិនោះ ដោយគ្មានរារែកឡើយ ។

សូមសហជីវិនជឿជាក់ចុះថា ក្នុងការប្រឆាំងនឹងអ្នកដែលប្រឆាំងផលប្រយោជន៍វប្បធម៌ជាតិ ប្រឆាំងនឹងគោលជំហរខាងលើរបស់សហជីវិន សហជីវិនមានមិត្តអ្នកគាំទ្រសហជីវិនច្រើនណាស់ ចាប់តាំងពីបញ្ញវ័ន្ត យុវជនរហូតដល់ប្រជារាស្ត្រ នឹងព្រះសង្ឃទាំងមូល ។ ការសិក្សាជាភាសាជាតិថ្នង តាមខេមរនីយកម្ម គឺពិតជាផ្លូវត្រូវ ហើយត្រូវតែទទួលជោគជ័យនឹងកិត្តិយសជាដាច់ខាតនៅទីអវសាន ។

សូមសហជីវិនទទួលសេចក្តីសរសើរ នឹងការគាំទ្រឥតត្រើយត្រារបស់យើងខ្ញុំដោយសេចក្តីកក់ក្តៅ ។

ដោយមេត្រីភាពដ៏ជ្រាលជ្រៅ

ប្រធានគណៈកម្មាធិការនាយកសមាគមកម្ពុជបុត្រ

## ... ពីគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃចលនាអក្ខរកម្ម

ប្រធានគណៈកម្មការបច្ចេកទេស នៃគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ នៃចលនាអក្ខរកម្ម

មកប្រធានគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ ក្រុងភ្នំពេញ

*កម្មវត្ថុ : ការបើកបង្រៀនអនក្ខរជន*

*យោង : លិខិតលេខ ៩ គ ន-១០ ចុះថ្ងៃទី ១០ មិនា ១៩៦៧*

*ខ្ញុំមានសេចក្ដីសោមនស្សជាពន់ពេក ចំពោះការផ្ដើមគំនិតដ៏ប្រពៃ នៃសមាគមសាស្ត្រាចារ្យខ្មែរ ដែលបានជួយទប់ស្កាត់ទៅតាមមធ្យោបាយដែលខ្លួនមាននូវយុទ្ធការណ៍ បំបាត់អនក្ខរភាព ដើម្បីឱ្យបានស្របទៅតាមសេចក្ដីត្រូវការរបស់ប្រទេសជាតិ នឹងព្រះរាជនយោបាយ នៃ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ។*

*សូមសហជីវិន នឹងសមាជិកនៃគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ ទទួលនូវសេចក្ដីគប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។*

ឈ្យូក មុឹងមៅ

## ... ពីអនុវិទ្យាល័យឈ្យូក (កំពត)

ចាងហ្វាងអនុវិទ្យាល័យឈ្យូក កំពត

មកសហជីវិនគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ ភ្នំពេញ

*កម្មវត្ថុ : សេចក្ដីថ្លែងអំណរគុណ*

*ក្នុងនាមសហការីទាំងអស់ នឹងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះសហជីវិនដែលបានផ្ដល់ជំនួយជាប្រាក់ដ៏ថ្លៃថ្លា ក្នុងឱកាសធ្វើឈាបនកិច្ចសពលោក យន់ ហួន សាស្ត្រាចារ្យអនុវិទ្យាល័យឈ្យូក ដែលបានអនិច្ចកម្មដោយគ្រោះថ្នាក់រថយន្ត នៅថ្ងៃទី ៩ មករា ១៩៦៧ នេះ ។*

## ហិបប្រាក់សមាគម ( តមកពីទំព័រ ៨២ )

*យើងទើបនឹងទទួលវិភាគទាន ដែលមកដល់ថ្មីៗទៀត ដូចតទៅ :*

| | |
|---|---|
| ទីចាត់ការសាកលវិទ្យាល័យភូមិន្ទ | 160 រៀល |
| សាស្ត្រាចារ្យមហាវិទ្យាល័យគរុកោសល្យ | 760 — |
| និស្សិតសាស្ត្រាចារ្យ | 1980 — |
| អនុវិទ្យាល័យ សាលាលេខប្រាំ ( កំពង់ឆ្នាំង ) | 320 — |
| — ស្ទឹងត្រង់ ( កំពង់ចាម ) | 466 — |
| — ក្រូចឆ្មា ( កំពង់ចាម ) | 1600 — |

★

## អំពីដំណឹងចុះថ្លៃសៀវភៅ

*មានបណ្ណាគារខ្លះ ដែលកាលពីដើម បានព្រមព្រៀងចុះថ្លៃសៀវភៅ ចំពោះសមាជិក ស. ស. ខ. យើង ប៉ុន្តែដល់ពេលក្រោយមក ក៏ធ្វើព្រងើយកន្តើយ ចំពោះមិត្តយើងទៅវិញ ។*

*ហេតុនេះ សូមមិត្តយើងអភ័យទោស ហើយសូមសំគាល់ថា បណ្ណាគារទាំងឡាយ ដែលមានចុះផ្សាយ ក្នុងទស្សនាវដ្ដីយើងលេខនេះតែប៉ុននោះ ដែលប្រាកដជានឹងចុះថ្លៃសៀវភៅជូនមិត្ត :*

---

## សូមមិត្តចុះឈ្មោះចូលជាសមាជិកនៃហិបសង្គ្រោះយើង

# ដំណឹងអនុគ្រោះ

បណ្ណាគារទាំងឡាយខាងក្រោមនេះ មានសេចក្ដីរីករាយ នឹងចុះថ្លៃសៀវភៅចំពោះសមាជិក ស. ស. ខ ដូចតទៅ :

| | | | |
|---|---|---|---|
| បណ្ណាគារតាអ៊ី | ចុះថ្លៃ | 10% | ចំពោះសៀវភៅបរទេស |
| 443 មហាវិថីព្រះមុនីវង្ស | – | 20% | – សៀវភៅខ្មែរ |
| បណ្ណាគារវិជ្ជាសាកល | – | 10% | – សៀវភៅខ្មែរ |
| 257 មហាវិថីព្រះសីហនុ | | | |
| បណ្ណាគារសុភមិត្រ | – | 10% | – សៀវភៅខ្មែរ |
| 367 C. ផ្លូវកម្ពុជាក្រោម | | | |
| បណ្ណាគារ គីម គី | – | 20% | – សៀវភៅខ្មែរ |
| 95 វិថីព្រះយុគន្ធរ | | | |
| បណ្ណាគារ គិម សេង | – | 20% | – សៀវភៅខ្មែរ |
| 223 មហាវិថីព្រះមុនីវង្ស | | | |
| ខេមរបណ្ណាគារ | – | 15% | – សៀវភៅខ្មែរ |
| 174 វិថីខេមរភូមិន្ទ | | | |

## ដំណឹងបន្ថែម

*សហករណ៍និស្សិត បានបើកទ្វារលក់ហើយ នៅផ្ទះលេខ ២៤ ផ្លូវសម្ដេចប៉ុន មានគ្រឿងឧបភោគ បរិភោគ គ្រប់មុខ*

*សូមអញ្ជើញមិត្តសាស្ត្រាចារ្យយើងជួយឧបត្ថម្ភផង ។*

បានដម្កល់ទុកតាមច្បាប់ត្រឹមត្រូវ

អនុញ្ញាតលេខ ១៩៤ ចុះថ្ងៃទី ២៨ – ៤ – ៦៧

បោះពុម្ពលើកទី ១ ចំនួន ១.៤០០ ក្បាល ។